# ព្រះរាជក្រម

នស/រកម/១១០៥/០៣៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាអង្គការសហប្រជា-ជាតិស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

## ស្ដីពី

## ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃ
## អនុសញ្ញារបស់អង្គការសហប្រជាជាតិស្ដីពីការប្រឆាំង
## បទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញារបស់អង្គការសហប្រជាជាតិស្ដីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងសម័យប្រជុំលើកទី ៥៥ តាមសេចក្ដីសម្រេចលេខ ៥៥/២៥ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០០ នៅទីក្រុងញូវយ៉ក ហើយដែលព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខាចូលជាភាគី នាថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០១ ដូចមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥

**ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ**

៣/រាល.០៤១១.៥០៥ **នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា ព្រះហស្ថលេខា**

**ស ខេង នរោត្តម សិរីវុឌ្ឍ**

លេខ : ៥៧៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សោ ឌី តាន់**

# អនុសញ្ញារបស់អង្គការសហប្រជាជាតិ
# ស្តីពីការប្រឆាំងទៅនឹងបទឧក្រិដ្ឋកម្មឆ្លងដែន
# ដែលមានអង្គការចាត់តាំង

អត្ថបទដែលដកស្រង់ពីច្បាប់ដើម ការថតចម្លងនេះត្រូវ
បានបញ្ជាក់ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ
នឹងត្រូវបានគេចេញផ្សាយនៅពេលក្រោយ

អង្គការសហប្រជាជាតិ

២០០០

**អនុសញ្ញារបស់អង្គការសហប្រជាជាតិ**
**ស្តីពីការប្រឆាំងទៅនឹងបទឧក្រិដ្ឋកម្មឆ្លងដែន**
**ដែលមានអង្គការចាត់តាំង**

**មាត្រា ១**
**អំពីគោលបំណង**

គោលបំណងនៃអនុសញ្ញានេះគឺដើម្បីជម្រុញកិច្ចសហប្រតិបត្តិការ បង្កានិងប្រយុទ្ធប្រឆាំងទៅនឹងបទឧក្រិដ្ឋឆ្លងដែនអោយមានប្រសិទ្ធិភាពខ្ពស់ ។

**មាត្រា ២**
**ការប្រើប្រាស់ពាក្យសំពួ**

គោលបំណងទាំងឡាយនៃអនុសញ្ញានេះគឺ :

a)-"ក្រុមឧក្រិដ្ឋជន" មានន័យថា ក្រុមមនុស្សបីនាក់ ឬច្រើននាក់ដែលបានបង្កើតឡើង ដោយប្រើប្រាស់ពេលវេលាហើយធ្វើសកម្មភាពរួមគ្នាតាមបំណងនៃការប្រព្រឹត្តបទព្រហ្មទណ្ឌធ្ងន់ធ្ងរមួយឬច្រើនឬបទល្មើសទាំងឡាយណាដូចមានចែងអនុលោមតាមអនុសញ្ញានេះដើម្បីទទួលនូវប្រយោជន៍ហិរញ្ញវត្ថុ ឬប្រយោជន៍សំភារៈដទៃទៀតដោយផ្ទាល់ ឬដោយប្រយោល ។

b)-"បទឧក្រិដ្ឋធ្ងន់ធ្ងរ" មានន័យថាការប្រព្រឹត្តនូវបទល្មើសដែលអាចផ្តន្ទាទោស ដោយការដកហូតសេរីភាពជាអតិបរមា យ៉ាងតិច ៤ ឆ្នាំ ឬទណ្ឌកម្មធ្ងន់ធ្ងរជាងនេះ ។

c)-ក្រុមដែលបានបង្កើតជារចនាសម្ព័ន្ធ មានន័យថា ជាក្រុមមួយដែលមិនត្រូវបានបង្កើតឡើងដោយកម្រដើម្បីកម្រៃជើងសារពីបទល្មើសភ្លាមៗ ហើយដែលមិនត្រូវការកំណត់តួនាទីជាផ្លូវការ ចំពោះសមាជិករបស់ខ្លួន និរន្ត-ភាពនៃសមាជិកភាពរបស់ខ្លួន ឬរចនាសម្ព័ន្ធដែលបានអភិវឌ្ឍន៍។

d)-កម្មសិទ្ធ មានន័យថា បណ្តាទ្រព្យគ្រប់ប្រភេទ ទោះជារូបិយ អរូបិយ ចលនទ្រព្យ ឬអចលនទ្រព្យ រូបិយប័ណ្ណ ឬអរូបិយប័ណ្ណ និងបណ្តាឯកសារច្បាប់ ឬកសារជាតឹកតាងដល់ ឬចាត់ជាទ្រព្យ ។

e)-ប្រាក់ចំណូលដោយបទព្រហ្មទណ្ឌ មានន័យថា ទ្រព្យសម្បត្តិណាមួយមានប្រភពមកពី ឬបានទទួលដោយផ្ទាល់ ឬប្រយោលតាមកម្រៃជើងសារបទល្មើស ។

f)-ការផ្អើបទុក ឬការកាន់កាប់ មានន័យថា ការហាមឃាត់ជាបណ្តោះអាសន្ននូវការផ្ទេរ ការប្តូរ ការជម្រុះចោល ឬចលនាទ្រព្យសម្បត្តិ ឬការបន្តឃុំឃាំង ឬគ្រប់គ្រងទ្រព្យសម្បត្តិជាបណ្តោះអាសន្ន តាមគោលការណ៍នៃបទបញ្ជា ដែលចេញដោយតុលាការឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត ។

g)-ការរឹបអូសយក ដែលដាក់បញ្ចូលទាំងការដកសិទ្ធិ ដែលអាចធ្វើទៅបាន មានន័យថា ការដកហូតយកទ្រព្យសម្បត្តិជាអចិន្ត្រៃយ៍ ដោយដីការបស់តុលាការ ឬដោយបទបញ្ជារបស់អាជ្ញាធរមានសមត្ថកិច្ច ។

h)-បទល្មើសសំអាង មានន័យថា បទល្មើសណាមួយជាលទ្ធផលដែលប្រាក់ចំណេញត្រូវបានបង្កើតឡើងដែលអាចជាប្រធានបទនៃបទល្មើស ដូចបានចែងក្នុងមាត្រាទី ៦ នៃអនុសញ្ញានេះ ។

i)-ការប្រគល់ទំនិញ ដែលបានកាន់កាប់ មានន័យថា ជាទេពកោសល្យនៃការអនុញ្ញាតអោយបេសកកម្មទាំងឡាយដែលសង្ស័យ ឬដែលខុសច្បាប់ ដើម្បីយកចេញ ឆ្លងកាត់ ឬចូលក្នុងទឹកដីនៃរដ្ឋមួយ ឬរដ្ឋច្រើន ដោយមានការដឹងឮស្ថិតក្រោមការត្រួតពិនិត្យនៃអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ។

j)-អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ មានន័យថា ជាអង្គការមួយបានបង្កើតឡើងដោយបណ្តារដ្ឋមានអធិបតេយ្យភាពរបស់តំបន់ដែលបានផ្តល់អោយ ដែលបណ្តារដ្ឋជាសមាជិករបស់ខ្លួនបានផ្ទេរសមត្ថកិច្ចចំពោះលក្ខណៈទាំងឡាយគ្របដណ្តប់អនុសញ្ញានេះ ហើយដែលត្រូវបានអនុញ្ញាតត្រឹមត្រូវ ស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ដើម្បីចុះហត្ថលេខា អោយសច្ចានុម័ត ទទួល ឯកភាព ឬយល់ព្រមចំពោះបញ្ហានេះ ។ ឯកសារយោងទាំងឡាយចំពោះភាគី

រដ្ឋជាសមាជិកទាំងឡាយស្ថិតក្រោមអនុសញ្ញានេះ ត្រូវអនុវត្តចំពោះអង្គការទាំងអស់ តាមការកំណត់នានាអំពីសមត្ថកិច្ចរបស់ខ្លួន ។

## មាត្រា ៣
## វិសាលភាពនៃការដាក់ពាក្យសុំ

១-អនុសញ្ញានេះត្រូវអនុវត្តចំពោះការទប់ស្កាត់ ការស្រាវជ្រាវ ការស៊ើបអង្កេត ការចោទប្រកាន់ លើកលែងតែគ្មានចែងនៅទីនេះ :

a)-បណ្តាបទល្មើសបានចែង អនុលោមតាមមាត្រា ៥ ៦ ៨ និង ២៣ នៃអនុសញ្ញានេះ និង

b)-បទឧក្រិដ្ឋកម្រិតធ្ងន់ ដូចមានចែងក្នុងមាត្រា ២ នៃអនុសញ្ញានេះ ដែលបទល្មើសមានជាលក្ខណៈឆ្លងដែន ហើយពាក់ព័ន្ធក្រុមឧក្រិដ្ឋជន ។

២-ចំពោះគោលបំណងនៃកថាខ័ណ្ឌ ១ នៃមាត្រានេះ បទល្មើសមួយមានលក្ខណៈឆ្លងដែន ប្រសិនបើ:

a)-វាត្រូវបានប្រព្រឹត្តក្នុងរដ្ឋលើសពីមួយ

b)-វាត្រូវបានប្រព្រឹត្តក្នុងរដ្ឋមួយ តែផ្នែកដែលគួរអោយយកចិត្តទុកដាក់គឺការរៀបចំ ការដាក់ផែនការ ទិសដៅ ឬការគ្រប់គ្រងកើតឡើងនៅរដ្ឋមួយផ្សេងទៀត ។

c)-វាត្រូវបានប្រព្រឹត្តក្នុងរដ្ឋមួយ ប៉ុន្តែពាក់ព័ន្ធទៅនឹងក្រុមឧក្រិដ្ឋជនដែលទាក់ទងទៅនិងសកម្មភាពឧក្រិដ្ឋនានាក្នុងរដ្ឋលើសពីមួយ ។

d)-វាត្រូវបានប្រព្រឹត្តក្នុងរដ្ឋមួយ ប៉ុន្តែមានអានុភាពធំធេងក្នុងរដ្ឋមួយផ្សេងទៀត ។

## មាត្រា ៤
## ការការពារអធិបតេយ្យភាព

១-បណ្តាភាគីរដ្ឋជាសមាជិកទាំងអស់ត្រូវដោះស្រាយដោយការទទួលខុសត្រូវ តាមអនុសញ្ញានេះក្នុងលក្ខណៈដែលស្របទៅតាមបណ្តាគោលការនៃសមភាព អធិបតេយ្យភាព និងបូរណភាពទឹកដីនៃរដ្ឋទាំងនោះ ហើយដែលមិនមានការធ្វើអន្តរាគមន៍ទៅលើ កិច្ចការផ្ទៃក្នុងនៃរដ្ឋដទៃឡើយ ។

២-មិនមានក្នុងអនុសញ្ញានេះទេ ការផ្តល់សិទ្ធដល់ភាគីរដ្ឋជាសមាជិកមួយ ដើម្បីទទួលខុសត្រូវក្នុងទឹកដីរដ្ឋជាសមាជិកមួយទៀត នូវការអនុវត្តតាមសមត្ថកិច្ច ឬការបំពេញមុខងារនានាដែលត្រូវបានរក្សាទុកផ្តាច់មុខ សម្រាប់អាជ្ញាធរទាំងឡាយនៃរដ្ឋដទៃទៀតដោយច្បាប់របស់ខ្លួន ។

## មាត្រា ៥
## ការដាក់ជាបទល្មើសព្រហ្មទណ្ឌនូវការចូលរួមក្នុងក្រុមឧក្រិដ្ឋជន

១-ភាគីរដ្ឋនីមួយៗត្រូវអនុម័តជាបទបញ្ញត្តិ និងបណ្តាវិធានការដទៃទៀតតាមដែលចាំបាច់ ដើម្បីបង្កើតជាបទល្មើសព្រហ្មទណ្ឌនៅពេលបានប្រព្រឹត្តដោយចេតនា

a)-ពីក្នុងចំណោមខាងក្រោមនោះ ជាបទល្មើសព្រហ្មទណ្ឌ ខុសពីបទល្មើសព្រហ្មទណ្ឌដែលទាក់ទិនដល់ការព្យាយាមបំពេញសកម្មភាពឧក្រិដ្ឋ ។

i)-ការព្រមព្រៀងជាមួយមនុស្សម្នាក់ ឬច្រើននាក់ ដើម្បីប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរ ក្នុងគោលបំណងទាក់ទងដល់ការទទួលនូវផលប្រយោជន៍ហិរញ្ញវត្ថុ ឬសំភារៈផ្សេងៗដោយផ្ទាល់ ឬដោយប្រយោល ហើយដែលបានតម្រូវដោយច្បាប់ក្នុងស្រុកពាក់ព័ន្ធនឹងការទទួលខុសត្រូវដោយអ្នកចូលរួមណាមួយក្នុងចំណោមទាំងអស់ តាមកម្រិតនៃកិច្ចព្រមព្រៀង ឬពាក់ព័ន្ធនឹងក្រុមឧក្រិដ្ឋជន ។

ii)-ការប្រព្រឹត្តដោយមនុស្សម្នាក់ដែលបានដឹងពីបំណង និងសកម្មភាពឧក្រិដ្ឋជាទូទៅរបស់ក្រុមឧក្រិដ្ឋជន ឬចេតនារបស់ខ្លួនដើម្បីប្រព្រឹត្តបទឧក្រិដ្ឋទាំងឡាយដែលលើកឡើង រួមចំណែកយ៉ាងសកម្មក្នុង :

a)-សកម្មភាពទាំងឡាយរបស់ក្រុមឧក្រិដ្ឋជន ។

b)-សកម្មភាពដទៃទៀតរបស់ក្រុមឧក្រិដ្ឋជន ដោយដឹងថាការចូលរួមរបស់ខ្លួននឹងជួយដល់សមិទ្ធិផលនៃគោលបំណងឧក្រិដ្ឋដែលបានរៀបរាប់ខាងលើ ។

c)-ការចាត់ចែង ការដឹកនាំ ការជួយទំនុកបំរុង ការជួយផ្តល់លក្ខណៈងាយស្រួល ឬការអោយដំបូន្មានលើការប្រព្រឹត្តល្មើសព្រហ្មទណ្ឌកម្រិតធ្ងន់ពាក់ព័ន្ធទៅនឹងក្រុមឧក្រិដ្ឋជន ។

២-ការដឹងឮ ចេតនា ការប៉ុនប៉ង គោលបំណង ឬការព្រមព្រៀងបានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ អាចសន្និដ្ឋានបានពីស្ថានការណ៍ដែលផ្តោតជាបត្យានុម័ត ។

៣-ភាគីរដ្ឋទាំងឡាយដែលច្បាប់ក្នុងស្រុករបស់ខ្លួនតម្រូវនូវការពាក់ព័ន្ធរបស់ពួកឧក្រិដ្ឋជន ដើម្បីបំពេញគោលបំណងនៃបទល្មើសទាំងឡាយ បានចែងស្របតាមកថាខ័ណ្ឌ ១ (a) (i) នៃមាត្រានេះ ត្រូវអះអាងថាច្បាប់ស្រុករបស់ខ្លួនគ្របដណ្តប់បទឧក្រិដ្ឋកម្រិតធ្ងន់ទាំងអស់ពាក់ព័ន្ធនឹងពួកឧក្រិដ្ឋជន។ ភាគីរដ្ឋទាំងអស់នោះក៏ដូចជាភាគីរដ្ឋទាំងឡាយដែលច្បាប់ស្រុករបស់ខ្លួនតម្រូវនូវអំពើក្នុងការនាំមុខនៃការព្រមព្រៀង ដើម្បីគោលបំណងទាំងឡាយនៃបទល្មើសនានាបានចែងស្រមតាម កថាខ័ណ្ឌ ១ (a) (i) នៃមាត្រានេះ ត្រូវរាយការណ៍ការពិតដល់អគ្គលេខាធិការរបស់អង្គការសហប្រជាជាតិ នៅពេលដែលមានការចុះហត្ថលេខារបស់ខ្លួន ឬនៅពេលដែលដាក់អោយធ្វើសច្ចាប័ន ការទទួល ការអនុម័ត ឬការឈានចូលអនុសញ្ញានេះ ។

## មាត្រា ៦
## ការចាត់ជាបទល្មើសព្រហ្មទណ្ឌចំពោះការលាងលុយកខ្វក់

១-រដ្ឋនិមួយៗដែលជាសមាជិកត្រូវតែអនុម័តដោយស្របតាមគោលការណ៍គ្រឹះទាំងឡាយ នៃច្បាប់របស់ខ្លួននូវបទបញ្ញត្តិ ហើយនឹងបណ្តាវិធានការដទៃទៀតដែលចាំបាច់ដើម្បីចាត់ជាបទល្មើសព្រហ្មទណ្ឌ កាលណាបានប្រព្រឹត្តដោយចេតនា :

a)(i)-ការប្តូរ ឬការផ្ទេរកម្មសិទ្ធ ដោយដឹងថាកម្មសិទ្ធទាំងអស់នោះជាប្រាក់ចំណូលបានពីបទល្មើសចំពោះគោលបំណងនៃការបិទបាំង ការកែច្នៃភាពដើមនៃកម្មសិទ្ធិខុសច្បាប់ ឬការជួយបុគ្គលណាមួយដែលពាក់ព័ន្ធក្នុងការរកកម្រៃជើងសារនៃបទល្មើសសំអាងដើម្បីចៀសវាងពីផលវិបាកផ្នែកច្បាប់នៃសកម្មភាពរបស់ខ្លួន ។

(ii)-ការលាក់បាំង ការកែច្នៃប្រភពទីតាំង និន្នាការចលនា ឬភាពជាម្ចាស់កម្មសិទ្ធពិត ដោយដឹងថាកម្មសិទ្ធទាំងនេះបានមកពីបទល្មើស ។

b)-ផ្អែកលើគំនិតជាមូលដ្ឋានទាំងឡាយនៃប្រព័ន្ធច្បាប់របស់ខ្លួន

i)-ការទទួលបាន ឬការប្រើប្រាស់កម្មសិទ្ធ ដោយដឹងថាកម្មសិទ្ធទាំងនោះជាប្រាក់ចំណូលពីបទឧក្រិដ្ឋនៅពេលដែលខ្លួនទទួល

ii)-ការចូលរួម ការសេពគប់ជាមួយ ឬក៏ការរួមធ្វើអំពើទុច្ចរិត ដើម្បីប្រព្រឹត្ត ការប៉ុនប៉ងដើម្បីប្រព្រឹត្ត និងការជួយទំនុកបំរុង ការជួយជ្រោមជ្រែង ការផ្តល់លក្ខណៈងាយស្រួល និងការផ្តល់យោបល់ពីការប្រព្រឹត្តបទល្មើសណាមួយបានចែងអនុលោមតាមមាត្រានេះ ។

២-ចំពោះគោលបំណងទាំងឡាយនៃការអនុវត្ត ឬប្រតិបត្តិកថាខ័ណ្ឌ ១ នៃមាត្រានេះ :

a) ភាគីរដ្ឋនីមួយៗត្រូវរិះរកដើម្បីអនុវត្តកថាខ័ណ្ឌ ១ នៃមាត្រានេះ ចំពោះដែនសមត្ថកិច្ចដ៏ទូលំទូលាយ នៃបណ្តាបទល្មើសសំអាង ។

b)-ភាគីរដ្ឋនីមួយៗត្រូវចាត់បញ្ចូលជាបទល្មើសសំអាងនូវបទព្រហ្មទណ្ឌកម្រិតធ្ងន់ទាំងអស់ដូចបានចែងក្នុងមាត្រា ២ នៃអនុសញ្ញានេះ ហើយបណ្តាបទល្មើសបានចែងស្របតាមមាត្រា ៥ ៨ និង ២៣ នៃអនុសញ្ញានេះ ។ ក្នុងករណីដែលរដ្ឋជាភាគីទាំងឡាយណាដែលបទបញ្ញត្តិរបស់ខ្លួន កត់ត្រាចូលក្នុងបញ្ជីបណ្តាបទល្មើសសំអាងជាក់ស្តែង ពួកគេត្រូវដាក់បញ្ចូលទៅក្នុងបញ្ជីនូវដែនសមត្ថកិច្ចទូលាយមួយនៃបណ្តាបទល្មើសដែលបានផ្សាភ្ជាប់ក្រុមឧក្រិដ្ឋជននូវកម្រិតអប្បបរមា ។

(c)-ចំពោះគោលបំណងនានានៃវាក្យខ័ណ្ឌ (b) បទល្មើសសំអាងត្រូវចាត់ចូលជាបទល្មើសដែលបានប្រព្រឹត្តក្នុង និងក្រៅវង្វង់យុត្តាធិការនៃភាគីរដ្ឋដែលមានបញ្ហា ទោះបីជាបណ្តាបទល្មើសប្រព្រឹត្តនៅក្រៅវង្វង់យុត្តាធិការនៃភាគីរដ្ឋមួយ ត្រូវចាត់ជាបទល្មើសសំអាងលុះណាតែការប្រព្រឹត្តដែលពាក់ព័ន្ធជាបទល្មើសព្រហ្មទណ្ឌ ដែលស្ថិតក្រោមច្បាប់របស់រដ្ឋមួយ កាលណាអំពើនេះត្រូវបានប្រព្រឹត្តក្នុងរដ្ឋនោះ ។

(d)-ភាគីរដ្ឋនីមួយៗត្រូវបានផ្តល់ការថតចម្លងច្បាប់របស់ខ្លួន ដែលផ្តល់សុពលភាពចំពោះមាត្រានេះ និងថតចម្លងការប្រែប្រួលបន្តបន្ទាប់ចំពោះច្បាប់ទាំងឡាយ ឬការអត្ថាធិប្បាយនៅទីនេះដល់អគ្គលេខាធិការអង្គការសហប្រជាជាតិ ។

(e)-ប្រសិនបើបានដាក់តម្រូវដោយគោលការណ៍គ្រឹះទាំងឡាយនៃច្បាប់របស់ភាគីរដ្ឋមួយ វាអាចត្រូវបានចាត់ជាបទល្មើស ដូចមានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ មិនអនុវត្តចំពោះបុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើសសំអាង ។

(f)-ការដឹងដោយចេតនា ឬប៉ុនប៉ងបានតម្រូវជាកម្មវត្ថុនៃបទល្មើស ដូចមានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ ត្រូវបានសន្និដ្ឋានដូចស្ថានភាពបត្យានុម័ត ។

## មាត្រា ៧
## បណ្តាវិធានការណ៍ដើម្បីប្រឆាំងការលាងលុយ

១-បណ្តារដ្ឋដែលជាសមាជិកទាំងអស់ត្រូវៈ

(a)-បង្កើតបទបញ្ញត្តិរបស់ខ្លួនដែលទូលំទូលាយ និងរបបត្រួតពិនិត្យចំពោះធនាគារ និងបណ្តាស្ថាប័នហិរញ្ញវត្ថុដែលមិនមែនជាធនាគារ ហើយកន្លែងដែលសមរម្យអង្គការដទៃទៀត ជាពិសេសដែលងាយស្រួលដល់ការលាងលុយ ក្នុងសមត្ថកិច្ចរបស់ខ្លួនដើម្បីទប់ស្កាត់ និងស៊ើបអង្កេតបណ្តាទម្រង់ទាំងអស់នៃការលាងលុយដែលត្រូវការបញ្ជាក់ចំពោះអត្តសញ្ញាណភ្ញៀវ រក្សាការថតចម្លង និងរាយការណ៍ពីករណីដែលសង្ស័យ ។

(b)-ត្រូវធានាអំពីរដ្ឋបាល បទបញ្ញត្តិ ការប្រតិបត្តិច្បាប់ និងអាជ្ញាធរដទៃទៀតដែលពាក់ព័ន្ធទៅនឹងការប្រយុទ្ធប្រឆាំងការលាងលុយ (ការចាត់បញ្ចូលដែលសមស្របតាមច្បាប់របស់ខ្លួន និងអាជ្ញាធរយុត្តិធម៌) មានលទ្ធភាពដើម្បីប្រតិបត្តិការ និងផ្លាស់ប្តូរពត៌មាន នៅក្នុងប្រទេស និងអន្តរជាតិ តាមបណ្តាលក្ខខ័ណ្ឌបានពណ៌នាដោយច្បាប់របស់ខ្លួន ហើយទីបំផុតត្រូវពិចារណាបង្កើតស្ថាប័នស៊ើបអង្កេតហិរញ្ញវត្ថុមួយ ដោយចាត់ជាមជ្ឈមណ្ឌលជាតិមួយសម្រាប់ប្រមូលផ្តុំ វិភាគ និងផ្សព្វផ្សាយពត៌មានដោយផ្តោតទៅលើការលាងលុយដែលមានអានុភាព ។

២-បណ្តាភាគីរដ្ឋទាំងអស់ត្រូវពិចារណាលើការអនុវត្តនិងវិធានការដែលអាចធ្វើទៅបាន ដើម្បីស៊ើបអង្កេតលើការប្រែប្រួលនៃប្រាក់ និងសំភារៈដែលចរាចរត្រឹមត្រូវឆ្លងកាត់ព្រំដែនរបស់ខ្លួន ។ ផ្អែកលើការការពារសុវត្ថិភាព ចំពោះការប្រើប្រាស់ត្រឹមត្រូវនៃពត៌មាន និងដោយគ្មានការរាំងតាមមធ្យោបាយណាមួយដល់ចលនា ឬការផ្លាស់ប្តូរទីតាំងនៃដើមទុនតាមលក្ខណៈច្បាប់ ។ បណ្តាវិធានការទាំងនេះអាចរួមបញ្ចូលសេចក្តីត្រូវការរបស់បុគ្គលទាំងឡាយ ឬបណ្តាកិច្ចការពាណិជ្ជកម្ម ដែលដឹកជញ្ជូនឆ្លងកាត់ព្រំដែននៃសាច់ប្រាក់ និងសំភារៈគ្រប់គ្រាន់ ដែលបានពិគ្រោះយោបល់ត្រឹមត្រូវ ។

៣-ក្នុងការបង្កើតបទដ្ឋានក្នុងស្រុកមួយ និងរបបអត្ថាធិការកិច្ចតាមវាក្យស័ព្ទនៃមាត្រានេះ ដោយមិនប៉ះពាល់ដល់មាត្រាដទៃទៀតនៃអនុសញ្ញានេះ ។ បណ្តាភាគីរដ្ឋទាំងអស់ត្រូវអនុញ្ញាតអោយប្រើប្រាស់ជាគោលមាគ៌ាមួយ នូវការផ្តើមដែលពាក់ព័ន្ធដល់អង្គការតាមតំបន់ អន្តរតំបន់ និងពហុភាគីប្រឆាំងនឹងការលាងលុយ ។

៤-បណ្តាភាគីរដ្ឋទាំងអស់ត្រូវយកចិត្តទុកដាក់ពង្រឹង និងជម្រុញកិច្ចសហប្រតិបត្តិការជាអន្តរជាតិ តាមតំបន់ តំបន់រណប និងទ្វេភាគីរវាងការអនុវត្តច្បាប់យុត្តិធម៌ និងអាជ្ញាធរទាំងឡាយដែលមានបទដ្ឋានហិរញ្ញវត្ថុ ដើម្បីប្រយុទ្ធប្រឆាំងនឹងការលាងលុយកខ្វក់ ។

## មាត្រា ៨
## ការចាត់ជាបទល្មើសព្រហ្មទណ្ឌចំពោះអំពើពុករលួយ

១-ភាគីរដ្ឋនីមួយៗត្រូវអនុម័តបទបញ្ញត្តិ និងបណ្ដាវិធានការដទៃទៀតដែលចាំបាច់ ដើម្បីបង្កើតជាបទល្មើសព្រហ្មទណ្ឌនៅពេលបានប្រព្រឹត្តដូចជា :

(a)-ការសន្យាផ្ដល់ ឬការអោយដល់មន្ត្រីណាម្នាក់ដោយផ្ទាល់ ឬដោយប្រយោល នូវអត្ថប្រយោជន៍ដែលជ្រុលហួសហេតុសម្រាប់មន្ត្រីនោះ ឬក៏បុគ្គលម្នាក់ទៀត ឬនីតិបុគ្គល ដើម្បីអោយគេធ្វើសកម្មភាព ឬមិនអើពើដល់ការអនុវត្តភារកិច្ចផ្លូវការរបស់ខ្លួន ។

(b)-ការរែអង្គាស ឬការទទួលយកដោយមន្ត្រីសាធារណៈដោយផ្ទាល់ ឬដោយប្រយោល នូវអត្ថប្រយោជន៍ជ្រុលហួសហេតុសម្រាប់មន្ត្រីនោះខ្លួនឯង ឬបុគ្គលមួយទៀត ឬនីតិបុគ្គល ដើម្បីអោយមន្ត្រីនោះប្រព្រឹត្ត ឬទប់ទល់អំពីសកម្មភាពក្នុងការអនុវត្តកាតព្វកិច្ចជាផ្លូវការរបស់ខ្លួន ។

២-ភាគីរដ្ឋនីមួយៗត្រូវពិចារណាលើការអនុម័តបទបញ្ញត្តិ និងបណ្ដាវិធានការដទៃទៀតដែលចាំបាច់ ដើម្បីបង្កើតជាបទល្មើសព្រហ្មទណ្ឌ ប្រព្រឹត្តយោងតាមកឋាខ័ណ្ឌ ១ នៃមាត្រានេះ ពាក់ព័ន្ធនឹងមន្ត្រីសាធារណៈជាជនបរទេស ឬមន្ត្រីស៊ីវិលអន្តរជាតិ ។ ដូចនេះភាគីរដ្ឋនីមួយៗត្រូវពិចារណាអំពីការបង្កើតជាបទល្មើសព្រហ្មទណ្ឌទាំងឡាយ អំពីទម្រង់ផ្សេងៗនៃអំពើពុករលួយ ។

៣-ភាគីរដ្ឋនីមួយៗត្រូវអនុម័តផងដែរនូវបណ្ដាវិធានការដែលចាំបាច់ ដើម្បីបង្កើតជាបទល្មើសព្រហ្មទណ្ឌនូវការចូលរួមណាមួយរបស់អ្នកសមគំនិតក្នុងបទល្មើសដូចបានចែងស្របតាមមាត្រានេះ ។

៤-ចំពោះគោលបំណងទាំងឡាយក្នុងកឋាខ័ណ្ឌ ១ នៃមាត្រានេះ និងមាត្រាទី ៩ នៃអនុសញ្ញានេះ ។ មន្ត្រីទូទៅ មានន័យថា មន្ត្រី ឬបុគ្គលម្នាក់ដែលជាអ្នកផ្ដល់សេវាសាធារណៈ ដូចមានចែងក្នុងច្បាប់របស់ប្រទេសនោះ និងដូចបានអនុវត្តច្បាប់ព្រហ្មទណ្ឌរបស់ភាគីរដ្ឋដែលបុគ្គលចោទសួរបំពេញមុខនាទី។

## មាត្រា ៩
## បណ្ដាវិធានការប្រឆាំងអំពើពុករលួយ

១-បន្ថែមទៅលើបណ្ដាវិធានការដែលបានចែងក្នុងមាត្រានៃអនុសញ្ញនេះ ភាគីរដ្ឋនីមួយៗត្រូវតែអនុម័តនូវបទបញ្ញត្តិ បទដ្ឋានរដ្ឋបាល ឬបណ្ដាវិធានការដែលមានប្រសិទ្ធភាពផ្សេងៗទៀត ដើម្បីជម្រុញអាកប្បកិរិយា និងដើម្បីទប់ស្កាត់ ស៊ើបអង្កេត និងដាក់ទណ្ឌកម្មលើអំពើពុករលួយរបស់មន្ត្រីសាធារណៈទាំងឡាយ តាមទំហំនៃការប្រព្រឹត្តតាមច្បាប់របស់ប្រទេសខ្លួន ។

២-ភាគីរដ្ឋនីមួយៗត្រូវចាត់បណ្ដាវិធានការ ដើម្បីធានាអោយមានប្រសិទ្ធិភាព ដោយអាជ្ញាធរនានារបស់ខ្លួនក្នុងការការពារ ទប់ស្កាត់ ការស៊ើបអង្កេត និងការដាក់ទណ្ឌកម្មចំពោះអំពើពុករលួយរបស់មន្ត្រីនានា រួមបញ្ចូលនូវការផ្ដល់ឯករាជ្យភាពគ្រប់គ្រាន់ ដើម្បីទប់ទល់នូវការនាំចូលមិនសមរម្យលើសកម្មភាពទាំងឡាយរបស់ខ្លួន ។

## មាត្រា ១០
## ភាពទទួលខុសត្រូវរបស់បុគ្គលទាំងឡាយដែលស្របច្បាប់

១-ភាគីរដ្ឋនីមួយៗត្រូវអនុម័តវិធានការនានាតាមដែលចាំបាច់ ស្របតាមគោលការណ៍ច្បាប់របស់ខ្លួន ដើម្បីបង្កើតអោយមានការទទួលខុសត្រូវរបស់នីតិបុគ្គលទាំងឡាយ ចំពោះការចូលរួមចំណែកក្នុងឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលពាក់ព័ន្ធនឹងពួកឧក្រិដ្ឋជន និងចំពោះបណ្ដាបទល្មើសមានចែងអនុលោមតាមមាត្រា ៥ ៦ ៨ និង ២៣ នៃអនុសញ្ញានេះ។

២-ផ្អែកទៅលើបណ្ដាគោលការណ៍នៃច្បាប់របស់ភាគីរដ្ឋជាសមាជិក ភាពទទួលខុសត្រូវរបស់នីតិបុគ្គលទាំង-ឡាយអាចជាបទព្រហ្មទណ្ឌ បទល្មើសរដ្ឋប្បវេណី ឬបទល្មើសរដ្ឋបាល ។

៣-ភាពទទួលខុសត្រូវទាំងនេះមិនត្រូវប៉ះពាល់ដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ របស់រូបវ័ន្តបុគ្គលនានាដែលបានប្រព្រឹត្តបទល្មើសផ្សេងៗឡើយ ។

៤-ភាគីរដ្ឋនីមួយៗត្រូវធានាថា នីតិបុគ្គលទាំងឡាយប្រកាន់ខ្ជាប់ការទទួលខុសត្រូវអនុលោមតាមមាត្រានេះ ជាពិសេសគឺផ្អែកលើប្រសិទ្ធភាព សមភាព និងទណ្ឌកម្មព្រហ្មទណ្ឌ រួមទាំងទណ្ឌកម្មផ្នែករូបិយវត្ថុ ។

## មាត្រា ១១

## ការចោទប្រកាន់ ការវិនិច្ឆ័យទោស និង ទណ្ឌកម្ម

១-ភាគីរដ្ឋនីមួយៗត្រូវបង្កើតក្រុមមន្ត្រីសំខាន់ៗមួយចំនួន ដើម្បីទទួលខុសត្រូវអំពើបណ្តាបទល្មើសបានចែងស្របតាមមាត្រា ៥ . ៦ . ៨ និង ២៣ នៃអនុសញ្ញានេះ ទទួលខុសត្រូវចំពោះទណ្ឌកម្មទាំងឡាយដែលចូលជាធរមាននូវភាពនៃបទល្មើស ។

២-ភាគីរដ្ឋនីមួយៗត្រូវយកចិត្តទុកដាក់ ដើម្បីធានាអំពីអំណាចស្របច្បាប់ទាំងឡាយដែលជាឆន្ទានុសិទ្ធិអោយស្ថិតក្រោមច្បាប់ស្រុករបស់ខ្លួនទាក់ទងដល់ការចោទប្រកាន់នៃបុគ្គលទាំងឡាយចំពោះបទល្មើសនានាគ្របដណ្តប់ដោយអនុសញ្ញានេះត្រូវបានអនុវត្ត ដើម្បីពង្រីកប្រសិទ្ធភាពនៃការប្រតិបត្តិច្បាប់កំណត់ចំពោះបណ្តាបទល្មើសទាំងនោះ ហើយដោយការប្រុងប្រយ័ត្នគួរឱ្យជឿទុកចិត្តបានចំពោះ សេចក្តីត្រូវការដើម្បីទប់ស្កាត់នូវក្រុមបទល្មើសទាំងនេះ ។

៣-ក្នុងករណីបទល្មើសទាំងឡាយបានចែងស្របតាមមាត្រា ៥ ៦ ៨ និង ២៣ នៃអនុសញ្ញានេះភាគីរដ្ឋនិមួយៗត្រូវចាត់វិធានការសមស្រប ស្របតាមច្បាប់ស្រុករបស់ខ្លួនហើយដោយប្រុងប្រយ័ត្នបំផុតចំពោះសិទ្ធិការពារ ដើម្បីរិះរកការធានាអំពីលក្ខខ័ណ្ឌទាំងឡាយ បានដាក់ភ្ជាប់សេចក្តីសំរេចទាំងឡាយ អំពីការលើកលែងការកាត់ទោសដែលនៅសល់មិនទាន់សំរេចឬឧទ្ធរណ៍ពិចារណាតំរូវការការចាំបាច់ដើម្បីធានាពីវត្តមានចុងចោទនៅតំណាក់កាលព្រហ្មទ័ណ្ឌលើកក្រោយទៀត ។

៤-ភាគីរដ្ឋនីមួយៗត្រូវធានាអះអាងថាតុលាការរបស់ខ្លួន ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀតជាភស្តុតាងអំពីលក្ខណៈធ្ងន់ធ្ងរនៃបទល្មើសទាំងឡាយ គ្របដណ្តប់ដោយអនុសញ្ញានេះនៅពេលពិចារណា អំពីយថាហេតុនៃការដោះលែងជាមុន ឬ ការដោះលែងជាបណ្តោះអាសន្ន បុគ្គលទាំងឡាយដែលបានដាក់ទោសរួចនៃបទល្មើសទាំងឡាយ ។

៥-ភាគីរដ្ឋនីមួយៗត្រូវបង្កើតក្រោមច្បាប់ស្រុករបស់ខ្លួនទុរលក្ខន្តិកៈវែងមួយ អំពីការកំណត់ថេរៈវេលាដើម្បីផ្តើមនីតិវិធីសំរាប់បទល្មើសណាមួយគ្របដណ្តប់ដោយអនុសញ្ញានេះ ហើយថេរៈវេលាវែងជាងដែលជនល្មើសដែល បានចោទប្រកាន់បានគេចវេះពីរដ្ឋបាលយុត្តិធម៌ដែលត្រឹមត្រូវ ។

៦-ការគ្មានចែងក្នុងអនុសញ្ញានេះ និងប៉ះពាល់ដល់គោលការណ៍ដែលអធិប្បាយអំពីបណ្តាបទល្មើសបានចែងអនុលោមតាមអនុសញ្ញានេះ ហើយអត្ថាធិប្បាយអំពីការការពារតាមច្បាប់ដែលអាចអនុវត្តបាន ឬ គោលការណ៍ច្បាប់ដទៃទៀតត្រួតពិនិត្យភាពត្រឹមត្រូវតាមច្បាប់អំពីការប្រព្រឹត្ត ត្រូវរក្សាចំពោះច្បាប់ក្នុងស្រុករបស់ភាគីរដ្ឋមួយ ហើយបណ្តាបទល្មើសទាំងនេះត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសអនុលោមតាមច្បាប់នោះ ។

## មាត្រា ១២

## ការរឹបអូសយក និង ការដកហូតយក

១-ភាគីរដ្ឋទាំងឡាយត្រូវអនុម័តបណ្តាវិធានការនានាតាមដែលអាចចាំបាច់ ចំពោះវិសាលភាពដ៏ធំបំផុត

ដែលអាចធ្វើទៅបានដើម្បីជួយឱ្យមានការរឹបអូសយកនូវ :

 a-កំរៃនៃបទល្មើសឧក្រិដ្ឋទាញយកពីបណ្ដាបទល្មើសគ្របដណ្ដប់ដោយអនុសញ្ញានេះ ឬ កម្មសិទ្ធិតំលៃ នៃភាពស៊ីគ្នាណាមួយចំពោះកំរៃទាំងនេះ ។

b-កម្មសិទ្ធិ សំភារៈ ឬ លិខិតដទៃទៀត ប្រើប្រាស់ផ្ទៃក្នុង ឬ បានទុកបំរុងសំរាប់ប្រើប្រាស់ក្នុងបទល្មើសទាំងឡាយគ្របដណ្ដប់ដោយអនុសញ្ញានេះ ។

២-ភាគីរដ្ឋទាំងឡាយត្រូវអនុម័តបណ្ដាវិធានការដែលអាចចាំបាច់ ដើម្បីជួយធ្វើឱ្យបាននូវអត្តសញ្ញាណស្លាកស្នាមការដោះលែង ឬ ការរឹបអូសយកនូវអ្វីៗបានយោងតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ ចំពោះគោលបំណងនៃការរឹបអូសយកជាយថាហេតុ ។

៣-ប្រសិនណាចំណូលពីបទល្មើសត្រូវបានកែប្រែ ឬ ផ្លាស់ប្ដូរជាផ្នែកទាំងដុល ចូលជាកម្មសិទ្ធិដទៃទៀត កម្មសិទ្ធិទាំងនេះត្រូវទទួលខុសត្រូវដល់បណ្ដាវិធានការបានយោងតាមក្នុងមាត្រានេះជំនួសដោយប្រាក់ចូលទាំងនេះ ។

៤-ប្រសិនណាប្រាក់ចំណូលពីបទល្មើសត្រូវបានគេប្រគល់ជាមួយកម្មសិទ្ធិ ដែលបានទទួលពីប្រភពស្របច្បាប់ ទាំងឡាយត្រូវទទួលខុសត្រូវចំពោះការដកហូតយកអាស្រ័យលើតំលៃដែលបានប៉ាន់ប្រមាណ នៃប្រាក់ចំណូលច្របូកច្របល់ទាំងនេះ ដោយមិនប៉ះពាល់ដល់អំណាចដែលទាក់ទិននឹងការដោះលែង ឬ ការរឹបអូសយក ។

៥-ប្រាក់ចំណូល ឬ អត្ថប្រយោជន៍ដទៃទៀតបានទទួលពីប្រាក់ចំណូល នៃបទឧក្រិដ្ឋ ចេញពីកម្មសិទ្ធិក្នុងផ្នែកដែលប្រាក់ចំណូលពីបទឧក្រិដ្ឋត្រូវបានកែប្រែ ឬ បានផ្លាស់ប្ដូរ ឬ ចេញពីកម្មសិទ្ធដោយប្រាក់ចំណូលពីបទឧក្រិដ្ឋណាមួយត្រូវបានបញ្ចូនច្របល់ ត្រូវទទួលខុសត្រូវផងដែលចំពោះបណ្ដាវិធានការបានយោងក្នុងមាត្រានេះ ក្នុងលក្ខណៈដូចគ្នា ហើយចំពោះវិសាលភាពដូចគ្នាជាប្រាក់ចំណូលពីបទឧក្រិដ្ឋ ។

៦-ចំពោះបណ្ដាគោលបំណងនៃមាត្រានេះ និងមាត្រាទី ១៣ នៃអនុសញ្ញានេះភាគីរដ្ឋនីមួយៗត្រូវផ្ដល់អំណាចតុលាការរបស់ខ្លួន ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀតដើម្បីបញ្ជាធនាគារ ការថេតចំលងហិរញ្ញវត្ថុ ឬពាណិជ្ជកម្មត្រូវធ្វើឱ្យបានតាមលទ្ធភាពដែលអាចធ្វើទៅបាន ឬត្រូវបានរឹបអូសយក ។ បណ្ដាភាគីរដ្ឋទាំងឡាយមិនត្រូវពន្យារអំពីបរិវេណនៃការសំងាត់របស់ធនាគារ ។

៧-ភាគីរដ្ឋទាំងឡាយអាចពិចារណា អំពីលទ្ធភាពនៃសេចក្ដីត្រូវការដែលជនល្មើសបង្ហាញពីលក្ខណៈដើមត្រឹមត្រូវនៃប្រាក់ចំណូលពីបទឧក្រិដ្ឋដែលបានចោទប្រកាន់ ឬ កម្មសិទ្ធិដទៃទៀតដែលទទួលខុសត្រូវចំពោះការរឹបអូសចំពោះវិសាលភាពដែលតំរូវការមួយ គឺស្របតាមបណ្ដាគោលការណ៍នៃច្បាប់ស្រុករបស់ខ្លួន ហើយស្របតាមលក្ខណៈយុត្តិធម៌ និង នីតិវិធីផ្សេងៗទៀត ។

៨-បណ្ដាបញ្ញត្តិនៃមាត្រានេះ មិនត្រូវបកស្រាយឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីទី ៣ ឡើយ ។

៩-ប្រការដែលគ្មានក្នុងមាត្រានេះ នឹងប៉ះពាល់ដល់គោលការដែលបណ្ដាវិធានការដែលបានយោងត្រូវបានចែង និងអនុវត្តអនុលោមទៅតាម និងផ្អែកលើបញ្ញត្តិនានា នៃច្បាប់ស្រុករបស់ភាគីរដ្ឋនោះ ។

## មាត្រា ១៣

## កិច្ចសហប្រតិបត្តិការអន្តរជាតិ ចំពោះបណ្ដាគោលបំណងនៃការរឹបអូសយក

១-ភាគីរដ្ឋនីមួយៗដែលបានទទួលសំណើពីភាគីរដ្ឋមួយទៀតអំពី យុត្តាធិការ លើបទល្មើសគ្របដណ្តប់ដោយអនុសញ្ញានេះចំពោះការរឹបអូសប្រាក់ចំណូលពីឧក្រិដ្ឋកម្មសិទ្ធិ បរិក្ខារ ឬ លិខិតករណ៍នានាបានយោងក្នុងមាត្រា ១២ កថាខ័ណ្ឌ ១ នៃអនុសញ្ញានេះកើតឡើងក្នុងទឹកដីរបស់ខ្លួនចំពោះវិសាលភាពដ៏ធំបំផុតដែលអាចធ្វើទៅបានតាមប្រព័ន្ធច្បាប់ស្រុករបស់ខ្លួនត្រូវ :

a-ដាក់ស្នើសំណើដល់អាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនចំពោះគោលបំណង នៃការទទួលបទបញ្ជានៃការរឹបអូសយកហើយប្រសិនបើបទបញ្ជាត្រូវបានផ្តល់ឱ្យប្រសិទ្ធភាពចំពោះវា ។

b-លើកសំណើដល់អាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនតាមទស្សនៈចំពោះការផ្តល់ប្រសិទ្ធភាពរបស់វាចំពោះវិសាលភាពដែលបានស្នើសុំបញ្ជានៃការរឹបអូសយកចេញដោយតុលាការ ក្នុងដែនដីរបស់ភាគីរដ្ឋដែលកំពុងស្នើស្របតាមមាត្រា ១២ កថាខ័ណ្ឌ ១ នៃអនុសញ្ញានេះត្រឹមតែវាពាក់ព័ន្ធដល់ប្រាក់ចំណូលពីឧក្រិដ្ឋកម្ម កម្មសិទ្ធិ បរិក្ខារ ឬឯកសារច្បាប់ដទៃទៀតបានយោងក្នុងមាត្រា ១២ កថាខ័ណ្ឌ ១ បានកើតឡើងក្នុងទឹកដីនៃភាគីរដ្ឋដែលបានលើកស្នើ ។

២-តាមសំណើដែលបានធ្វើដោយភាគីរដ្ឋមួយទៀតមានយុត្តាធិការលើ បទល្មើសគ្របដណ្តប់ដោយអនុសញ្ញានេះ ។ ភាគីរដ្ឋដែលបានលើកសំណើត្រូវចាត់វិធានការ ដើម្បីកត់សំគាល់ស្លាកស្នាមហើយដោះលែង ឬ ដកហូតយកប្រាក់ចំណូលពីឧក្រិដ្ឋកម្ម កម្មសិទ្ធិ បរិក្ខារ ឬ ឯកសារច្បាប់នានា បានយោងក្នុងមាត្រា ១២ កថាខ័ណ្ឌ ១ នៃអនុសញ្ញានេះសំរាប់គោលបំណងនៃការដកហូតយកជាយថាហេតុ ត្រូវបានបញ្ជាក់ផងដែរដោយភាគីរដ្ឋដែល ដោយភាគីរដ្ឋដែលកំពុងស្នើសុំ ឬ ស្របតាមសំណើដែលស្ថិតក្រោមកថាខ័ណ្ឌ ១ នៃមាត្រានេះដោយភាគីរដ្ឋដែលបានស្នើសុំ ។

៣-បណ្តាបញ្ញត្តិក្នុងមាត្រាទី ១៨ នៃអនុសញ្ញានេះត្រូវអនុវត្តចំពោះមាត្រានេះ ។ ជាបន្ថែមចំពោះពត៌មាននេះបានបញ្ជាក់ក្នុងមាត្រា ១៨ កថាខ័ណ្ឌ ១៥ សំណើទាំងឡាយ បានធ្វើឡើងស្របតាមមាត្រានេះត្រូវផ្ទុក :

a-ក្នុងករណីសំណើមានជាប់ទាក់ទងទៅនឹងកថាខ័ណ្ឌ ១ (a) នៃមាត្រានេះការអធិប្បាយអំពីកម្មសិទ្ធ ត្រូវបានដកហូតយកហើយកំណត់ហេតុបានផ្អែកលើដោយ ភាគីរដ្ឋដែលកំពុងដាក់សំណើគ្រប់គ្រាន់ដើម្បីអាចឱ្យភាគី រដ្ឋ ដែលបានស្នើស្វែងរកបញ្ជាស្ថិតក្រោមច្បាប់ស្រុករបស់ខ្លួន ។

b-ក្នុងករណីសំណើជាប់ទាក់ទងទៅនឹងកថាខ័ណ្ឌ ១ ( b )នៃមាត្រានេះការថតចំលងដែលអាចយកជាការបានតាមច្បាប់នៃបញ្ជាអំពីការរឹបអូសយកផ្អែកលើសំណើដែលត្រូវយកជាគ្រឹះចេញដោយភាគីរដ្ឋដែលកំពុង លើកសំណើកំណត់ហេតុ និងពត៌មានជាវិសាលភាពចំពោះការលុបចោលបទបញ្ជាត្រូវបានស្នើឡើង ។

c-ក្នុងករណីសំណើជាប់ទាក់ទងនិងកថាខ័ណ្ឌ ២ នៃមាត្រានេះកំណត់ហេតុដែលបានផ្អែកដោយភាគីរដ្ឋ កំពុងស្នើសុំ និងការអធិប្បាយអំពីសកម្មភាពនានាដែលបានដាក់ស្នើ ។

៤-សេចក្តីសំរេចទាំងឡាយ ឬ សកម្មភាពទាំងឡាយបានផ្តល់ឱ្យក្នុងកថាខ័ណ្ឌ ១ និង ២ នៃមាត្រានេះត្រូវបានទទួលយកដោយភាគីរដ្ឋដែលបានស្នើសុំអនុលោមតាមនិងផ្អែកលើបញ្ញត្តិទាំងឡាយនៃច្បាប់ស្រុករបស់ខ្លួននិងបទបញ្ជាជានីតិវិធីរបស់ខ្លួន ឬ កតិកាសញ្ញាជាទ្វេភាគី ឬ ពហុភាគីកិច្ចព្រមព្រៀង ឬ ការរៀបចំចំពោះវាអាចជាប់ក្នុងទំនាក់ទំនង និងភាគីរដ្ឋដែលបានកំពុងស្នើសុំ ។

៥-ភាគីរដ្ឋនីមួយៗត្រូវផ្តល់ការថតចំលងទាំងឡាយ នូវច្បាប់និងបញ្ញត្តិទាំងឡាយរបស់ខ្លួនដែលផ្តល់សុពលភាពដល់មាត្រានេះ និងអំពីការប្រែប្រួលជាបន្តបន្ទាប់ចំពោះច្បាប់និងបញ្ញត្តិនានា ឬការអត្ថាធិប្បាយនេះដល់អគ្គលេខាធិការរបស់អង្គការសហប្រជាជាតិ ។

៦-ប្រសិនបើភាគីរដ្ឋមួយបោះឆ្នោតដើម្បីបង្កើតនូវការចាត់វិធានការ បានយោងក្នុងកថាខ័ណ្ឌ ១ និង ២ នៃមាត្រានេះមានលក្ខខ័ណ្ឌអំពីការមានកតិកាសញ្ញាដែលជាប់ពាក់ព័ន្ធ ភាគីរដ្ឋនោះត្រូវពិចារណាអំពីអនុសញ្ញានេះនូវកតិកាសញ្ញាចាំបាច់ និងគ្រាប់គ្រាន់ជាទៀងទាត់ ។

៧-កិច្ចសហប្រតិបត្តិការស្ថិតក្រោមមាត្រានេះ អាចត្រូវបដិសេធដោយភាគីរដ្ឋមួយប្រសិនបើបទល្មើសដែលសំណើរជាប់ទាក់ទងគ្នាមិនមែនជាបទល្មើសគ្របដណ្តប់ដោយអនុសញ្ញានេះ ។

៨-បទបញ្ញត្តិទាំងឡាយនៃមាត្រានេះមិនត្រូវបកស្រាយឱ្យប៉ះពាល់សិទ្ធិ នៃភាគីទី ៣ ដែលមិនក្លែងក្លាយ ។

៩-ភាគីរដ្ឋទាំងឡាយត្រូវពិចារណាអំពីការសន្និដ្ឋានសន្និសញ្ញាទ្វេភាគីឬពហុភាគីកិច្ចព្រមព្រៀង ឬការចាត់ចែងរៀបចំដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព នៃកិច្ចសហប្រតិបត្តិការជាអន្តរជាតិ ដែលបានទទួលរ៉ាប់រងស្របតាមមាត្រានេះ ។

## មាត្រា ១៤

## ការកំចាត់ចោលប្រាក់ចំណូលពីឧក្រិដ្ឋកម្ម ឬ កម្មសិទ្ធិដែលរឹបអូស

១-ប្រាក់ចំណូលពីឧក្រិដ្ឋកម្ម ឬ កម្មសិទ្ធិបានដកហូតដោយភាគីរដ្ឋមួយស្របតាមមាត្រា ១២ ឬ ១៣ កថាខ័ណ្ឌ ១ នៃអនុសញ្ញានេះត្រូវកំចាត់ចោលដោយភាគីរដ្ឋនោះ អនុលោមតាមច្បាប់ស្រុករបស់ខ្លួននិងបណ្តានីតិវិធីរដ្ឋបាលផ្សេងៗ ។

២-កាលណាអនុវត្តតាមសំណើរបានធ្វើឡើងដោយភាគីរដ្ឋមួយទៀត អនុលោមតាមមាត្រា១៣ នៃអនុសញ្ញានេះភាគីរដ្ឋទាំងឡាយត្រូវផ្តល់អាទិភាពដល់ការពិចារណា ចំពោះការប្រគល់ត្រលប់វិញនូវប្រាក់ចំណូលឧក្រិដ្ឋកម្ម ឬកម្មសិទ្ធិដែលបានរឹបអូសដល់ភាគីរដ្ឋដែលស្នើសុំនេះ វាអាចផ្តល់សំណងដល់អ្នករងគ្រោះដោយឧក្រិដ្ឋកម្ម ឬឱ្យត្រឡប់វិញប្រាក់ចំណូលនៃបទឧក្រិដ្ឋកម្ម ឬកម្មសិទ្ធិដល់ម្ចាស់ស្របច្បាប់របស់គេចំពោះក៏តែបានអនុញ្ញាតដោយច្បាប់ក្នុងស្រុកហើយប្រសិនបើបានស្នើដូច្នេះ ។

៣-កាលណាអនុវត្តតាមសំណើរធ្វើឡើងដោយភាគីរដ្ឋមួយទៀត ស្របតាមមាត្រា ១២ និង ១៣ នៃអនុសញ្ញានេះគាគីរដ្ឋមួយអាចផ្តល់ឱ្យនូវការពិចារណាជាពិសេសចំពោះការសន្និដ្ឋានកិច្ចព្រមព្រៀងនានា ឬការចាត់ចែងរៀបចំនានាអំពី :

 a-ការបរិច្ចាកតំលៃនៃប្រាក់ចំណូលពីបទឧក្រិដ្ឋ ឬ កម្មសិទ្ធិ ឬ ប្រាក់ផ្សេងៗបានពីការលក់ប្រាក់ចំណូលពីឧក្រិដ្ឋកម្ម ឬ......... ឬចំណែកមួយនៃផ្នែកនេះដល់គណនីដែលបានជ្រើសទុកជាមុនស្របតាមមាត្រា ៣០ កថាខ័ណ្ឌ ២ (c) នៃអនុសញ្ញានេះហើយដល់បណ្តាអង្គការអន្តររដ្ឋាភិបាលដែលកំពុងផ្តល់ឯកទេសកម្មក្នុងការប្រយុទ្ធប្រឆាំងបទឧក្រិដ្ឋកម្ម ។

b-ការចែកភាគហ៊ុនជាមួយភាគីរដ្ឋទាំងឡាយជាទៀងទាត់ ឬករណីតាមករណីដោយទៀងទាត់ប្រាក់ចំណូលពីឧក្រិដ្ឋកម្ម ឬទ្រព្យសម្បត្តិ ឬប្រាក់ដែលបានពីការលក់ប្រាក់ ឬទ្រព្យពីបទឧក្រិដ្ឋកម្មអនុលោមតាមច្បាប់ស្រុករបស់ខ្លួន ឬនីតិវិធីរដ្ឋបាលនានា ។

## មាត្រា ១៥
## អំពីយុត្តាធិការ

១-ភាគីរដ្ឋនិមួយៗត្រូវអនុវត្តបណ្តាវិធានការដែលអាចចាំបាច់ ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួនលើបទល្មើសទាំងឡាយបានចែងស្របតាមមាត្រា ៥ ៦ ៨ និង ២៣ នៃអនុសញ្ញានេះកាលណា :

a-បទល្មើសត្រូវបានកើតឡើងក្នុងទឹកដីរបស់ភាគីរដ្ឋនោះ ឬ

b-បទល្មើសត្រូវបានប្រព្រឹត្តនៅលើនាវា យន្តហោះដែលកំពុងហោះហើរមានទង់ជាតិរបស់ភាគីរដ្ឋនោះ ឬយន្តហោះដែលត្រូវបានគេចុះបញ្ជីស្ថិតក្រោមច្បាប់ទាំងឡាយរបស់ភាគីរដ្ឋនោះនៅពេលដែលបទល្មើសត្រូវបានកើតឡើង ។

២-ផ្អែកលើមាត្រាទី ៤នៃអនុសញ្ញានេះភាគីរដ្ឋមួយអាចបង្កើតផងដែរនូវយុត្តាធិការរបស់ខ្លួនទៅលើបទល្មើសកាលណា :

a-បទល្មើសត្រូវបានប្រព្រឹត្តប្រឆាំងជនជាតិ នៃភាគីរដ្ឋនេះ

b-បទល្មើសត្រូវបានប្រព្រឹត្តដោយជនជាតិ នៃភាគីរដ្ឋនោះ ឬជនដែលគ្មានរដ្ឋដែលមានទីលំនៅជាទំលាប់របស់គេក្នុងទឹកដីរបស់ខ្លួន ឬ

c-បទល្មើសជា :

i-បទល្មើសមួយក្នុងចំនោមទាំងនោះចែងស្របតាមមាត្រាកឋាខ័ណ្ឌ១ នៃអនុសញ្ញានេះហើយត្រូវបានប្រព្រឹត្តខាងក្រៅទឹកដីរបស់ខ្លួនដោយទស្សនៈចំពោះការប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរក្នុងទឹកដីរបស់ខ្លួន ។

ii-បទល្មើសមួយបានចែងស្របតាមមាត្រា៦ កឋាខ័ណ្ឌ១

b-ii -នៃអនុសញ្ញានេះហើយត្រូវបានសកើតឡើងខាងក្រៅទឹកដីរបស់ខ្លួនដោយទិដ្ឋភាពចំពោះការប្រព្រឹត្ត បទល្មើសបានចែងស្របតាមមាត្រាទី ៦ កឋាខ័ណ្ឌ១ (a- i) ឬ (ii) ឬ(b)(i) នៃអនុសញ្ញានេះនៅទឹកដីរបស់ខ្លួន

៣-ចំពោះបណ្តាគោលបំណងនៃមាត្រា ១៦ កឋាខ័ណ្ឌ ១០ នៃអនុសញ្ញានេះភាគីរដ្ឋនីមួយៗត្រូវអនុវត្តបណ្តាវិធានការដូចដែលអាចចាំបាច់ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួនលើបទល្មើសទាំងឡាយគ្របដណ្តប់ដោយអនុសញ្ញានេះនៅពេលដែលជនល្មើសដែលបានចោទប្រកាន់មានវត្តមានក្នុងទឹកដីរបស់ខ្លួនហើយវាមិនធ្វើបត្យាប័នបុគ្គលនេះម្នាក់ឯងស្ថិតលើកទឹកដីដែលគាត់ជាមនុស្សនៃសញ្ជាតិនោះ ។

៤-ភាគីរដ្ឋនិមួយៗអាចអនុវត្តផងដែរនូវបណ្តាវិធានការដូចដែលអាចចាំបាច់ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួនទៅលើបទល្មើសនានា គ្របដណ្តប់ដោយអនុសញ្ញានេះកាលណាជនល្មើសដែលបានចោទប្រកាន់មានវត្តមានក្នុងទឹកដីរបស់ខ្លួនហើយមិនធ្វើបត្យាប័នគាត់ទេ ។

b-ការចែកភាគហ៊ុនជាមួយភាគីរដ្ឋទាំងឡាយជាទៀងទាត់ ឬករណីតាមករណីដោយទៀងទាត់ប្រាក់ចំណូលពីឧក្រិដ្ឋកម្ម ឬទ្រព្យសម្បត្តិ ឬប្រាក់ដែលបានពីការលក់ប្រាក់ ឬទ្រព្យពីបទឧក្រិដ្ឋកម្មអនុលោមតាមច្បាប់ស្រុករបស់ខ្លួន ឬនីតិវិធីរដ្ឋបាលនានា ។

## មាត្រា ១៥

## អំពីយុត្តាធិការ

១-ភាគីរដ្ឋនិមួយៗត្រូវអនុវត្តបណ្តាវិធានការដែលអាចចាំបាច់ ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួនលើបទល្មើសទាំងឡាយបានចែងស្របតាមមាត្រា ៥ ៦ ៨ និង ២៣ នៃអនុសញ្ញានេះកាលណា :

a-បទល្មើសត្រូវបានកើតឡើងក្នុងទឹកដីរបស់ភាគីរដ្ឋនោះ ឬ

b-បទល្មើសត្រូវបានប្រព្រឹត្តនៅលើនាវា យន្តហោះដែលកំពុងហោះហើរមានទង់ជាតិរបស់ភាគីរដ្ឋនោះ ឬយន្តហោះដែលត្រូវបានគេចុះបញ្ជីស្ថិតក្រោមច្បាប់ទាំងឡាយរបស់ភាគីរដ្ឋនោះនៅពេលដែលបទល្មើសត្រូវបានកើតឡើង ។

២-ផ្អែកលើមាត្រាទី ៤នៃអនុសញ្ញានេះភាគីរដ្ឋមួយអាចបង្កើតផងដែរនូវយុត្តាធិការរបស់ខ្លួនទៅលើបទល្មើសកាលណា :

a-បទល្មើសត្រូវបានប្រព្រឹត្តប្រឆាំងជនជាតិ នៃភាគីរដ្ឋនេះ

b-បទល្មើសត្រូវបានប្រព្រឹត្តដោយជនជាតិ នៃភាគីរដ្ឋនោះ ឬជនដែលគ្មានរដ្ឋដែលមានទីលំនៅជាទំលាប់របស់គេក្នុងទឹកដីរបស់ខ្លួន ឬ

c-បទល្មើសជា :

i-បទល្មើសមួយក្នុងចំនោមទាំងនោះចែងស្របតាមមាត្រាកឋាខ័ណ្ឌ១ នៃអនុសញ្ញានេះហើយត្រូវបានប្រព្រឹត្តខាងក្រៅទឹកដីរបស់ខ្លួនដោយទស្សនៈចំពោះការប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរក្នុងទឹកដីរបស់ខ្លួន ។

ii-បទល្មើសមួយបានចែងស្របតាមមាត្រា៦ កឋាខ័ណ្ឌ១

b-ii –នៃអនុសញ្ញានេះហើយត្រូវបានសកើតឡើងខាងក្រៅទឹកដីរបស់ខ្លួន ដោយទិដ្ឋភាពចំពោះការប្រព្រឹត្ត បទល្មើសបានចែងស្របតាមមាត្រាទី ៦ កឋាខ័ណ្ឌ១ (a- i) ឬ (ii) ឬ(b)(i) នៃអនុសញ្ញានេះនៅទឹកដីរបស់ខ្លួន

៣-ចំពោះបណ្តាគោលបំណងនៃមាត្រា ១៦ កឋាខ័ណ្ឌ ១០ នៃអនុសញ្ញានេះភាគីរដ្ឋនីមួយៗត្រូវអនុវត្តបណ្តាវិធានការដូចដែលអាចចាំបាច់ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួនលើបទល្មើសទាំងឡាយគ្របដណ្តប់ដោយអនុសញ្ញានេះនៅពេលដែលជនល្មើសដែលបានចោទប្រកាន់មានវត្តមានក្នុងទឹកដីរបស់ខ្លួនហើយវាមិនធ្វើបត្យាប័នបុគ្គលនេះម្នាក់ឯងស្ថិតលើកទឹកដីដែលគាត់ជាមនុស្សនៃសញ្ជាតិនោះ ។

៤-ភាគីរដ្ឋនិមួយៗអាចអនុវត្តផងដែរនូវបណ្តាវិធានការដូចដែលអាចចាំបាច់ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួនទៅលើបទល្មើសនានា គ្របដណ្តប់ដោយអនុសញ្ញានេះកាលណាជនល្មើសដែលបានចោទប្រកាន់មានវត្តមានក្នុងទឹកដីរបស់ខ្លួនហើយមិនធ្វើបត្យាប័នគាត់ទេ ។

៥-ប្រសិនបើភាគីរដ្ឋមួយដែលកំពុងអនុវត្តយុត្តាធិការរបស់ខ្លួន ស្ថិតក្រោមកឋាខ័ណ្ឌ ១ និង ២ នៃមាត្រានេះបានត្រូវគេប្រកាស ឬទោះជាបានរៀនដែលភាគីរដ្ឋមួយឬច្រើនកំពុងដឹកនាំការស្រាវជ្រាវអង្កេតធ្វើការចោទប្រកាន់ ឬនីតិយុត្តិធម៌ចំពោះកាប្រព្រឹត្តដូចគ្នាអាជ្ញាធរមានសមត្ថកិច្ចនានារបស់ភាគីរដ្ឋទាំងនោះជាត្រឹមត្រូវត្រូវប្រឹក្សាយោបល់ជាមួយភាគីរដ្ឋមួយទៀតតាមទស្សនៈចំពោះការសំរបសំរួលសកម្មភាពទាំងឡាយរបស់ពួកខ្លួន ។

៦-ដោយមិនប៉ះពាល់ដល់បទដ្ឋាននានានៃច្បាប់អន្តរជាតិជាទូទៅ អនុសញ្ញានេះមិនត្រូវដាក់ចេញការអនុវត្តនូវយុត្តាធិការដែ្ឋកព្រហ្មទ័ណ្ឌណាមួយបានបង្កើតឡើងដោយភាគីរដ្ឋមួយស្របតាមច្បាប់ស្រុករបស់គេ ។

## មាត្រា ១៦

## ការធ្វើបត្យាប័ន

១-មាត្រានេះត្រូវអនុវត្តចំពោះបទល្មើសទាំងឡាយណាបានគ្របដណ្តប់ ដោយអនុសញ្ញានេះ ឬ ក្នុងបណ្តករណីដែលបទល្មើសបានយោងក្នុងមាត្រា៣ កឋាខ័ណ្ឌ ១ (a) ឬ (b) ពាក់ព័ន្ធនឹងក្រុមឧក្រិដ្ឋជន និងបុគ្គលដែលជាប្រធានបទនៃសំណើរចំពោះការធ្វើបត្យាប័នត្រូវបានបោះទីតាំងក្នុងទឹកដីនៃភាគីរដ្ឋដែលបានស្នើសុំ ប្រសិនបើបទរករណីដែលបទល្មើសបានយោងក្នុងមាត្រា៣ កឋាខ័ណ្ឌ១ ( a ) ឬ ( b ) ពាក់ព័ន្ធនឹងក្រុមឧក្រិដ្ឋជន និងបុគ្គលដែលជាប្រធានបទនៃសំណើរចំពោះការធ្វើបត្យាប័នត្រូវបានបោះទីតាំងក្នុងទឹកដីនៃភាគីរដ្ឋដែលបានស្នើសុំ ប្រសិនបើបទ-ល្មើសសំរាប់បត្យាប័នត្រូវបានរិះរកមានទ័ណ្ឌកម្មស្ថិតក្រោមច្បាប់ស្រុករបស់ភាគីទាំងពីរ ភាគិរដ្ឋដែលកំពុងស្នើ និងភាគីរដ្ឋ ដែលបានស្នើ ។

២-ប្រសិនបើសំណើរឱ្យធ្វើបត្យាប័នរួមបញ្ចូលបទល្មើសឧក្រិដ្ឋធ្ងន់ធ្ងរដាច់ពីគ្នាខ្លះ១ បទល្មើសខ្លះមិនគ្របដណ្តប់ដោយមាត្រានេះ ភាគីរដ្ឋដែលបានស្នើរអាចអនុវត្តមាត្រានេះផងដែរ ចំពោះបណ្តាបទល្មើសជាបន្តបន្ទាប់ទៀត ។

៣-បទល្មើសទាំងអស់ដែលមាត្រានេះអនុវត្ត ត្រូវយល់ថាត្រូវបានចាត់ជាបទល្មើសដែលធ្វើបត្យាប័នក្នុងសន្ធិសញ្ញាបត្យាប័នណាមួយកើតឡើងរវាងភាគីរដ្ឋទាំងនោះ ។ ភាគីរដ្ឋនានាធ្វើការបញ្ចូលបណ្តាបទល្មើសជាបណ្តាបទល្មើសដែលធ្វើបត្យាប័នក្នុងសន្ធិសញ្ញាបត្យាប័ននីមួយ១ត្រូវសន្និដ្ឋានចេញពីបទល្មើសទាំងនេះ ។

៤-ប្រសិនបើភាគីរដ្ឋមួយដែលធ្វើបត្យាប័នមានលក្ខខ័ណ្ឌស្របតាមសន្ធិសញ្ញា បានទទួលសំណើរដើម្បីធ្វើបត្យាប័នអាចពិចារណាអនុសញ្ញានេះជាមូលដ្ឋានច្បាប់សំរាប់ការធ្វើបត្យាប័នចំពោះបទល្មើសដែលមាត្រានេះអនុវត្ត ។

៥-ភាគីរដ្ឋទាំងឡាយដែលធ្វើបត្យាប័នមានលក្ខខ័ណ្ឌ លើប្រសិទ្ធិភាពនៃសន្ធិសញ្ញាមួយត្រូវ :

a-នៅពេលនៃការដាក់លិខិតស្នាមនៃការឱ្យសច្ចានុម័ត របស់ពួកគេ ការទទួល ការយល់ព្រម ឬ ការឈានចូលដល់អនុសញ្ញានេះរាយការណ៍ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិទោះជាពួកគេនិងទទួលយកអនុសញ្ញានេះជាមូលដ្ឋានច្បាប់សំរាប់កិច្ចសហប្រតិបត្តិការលើការធ្វើបត្យាប័នជាមួយភាគីរដ្ឋដទៃទៀតចំពោះអនុសញ្ញានេះហើយ

b-ប្រសិនណាពួកគេមិនទទួលយកអនុសញ្ញានេះ ជាមូលដ្ឋានច្បាប់សំរាប់កិច្ចសហប្រតិបត្តិការលើកការធ្វើបត្យាប័នរិះរកដែលសមរម្យ ដើម្បីសន្និដ្ឋានលើសន្ធិសញ្ញានានាលើការធ្វើបត្យាប័នជាមួយបណ្តាភាគីរដ្ឋដទៃទៀតចំពោះអនុសញ្ញានេះដើម្បីអនុវត្តមាត្រានេះ ។

៦-ភាគីរដ្ឋទាំងឡាយដែលមិនធ្វើបត្យាប័ន លើលក្ខខ័ណ្ឌប្រសិទ្ធភាព នៃសន្ធិសញ្ញាមួយត្រូវទទួលស្គាល់បណ្តាបទល្មើសណាមួយដែលមាត្រានេះអនុវត្តជាបណ្តាបទល្មើសដែលធ្វើបត្យាប័នរវាងពួកគេ ។

៧-ការធ្វើបត្យាប័នត្រូវផ្អែកលើលក្ខខ័ណ្ឌទាំងឡាយបានផ្តល់ឱ្យតាមរយៈច្បាប់ក្នុងស្រុករបស់ភាគីរដ្ឋដែលបានស្នើសុំ ឬដោយសន្ធិសញ្ញាការធ្វើបត្យាប័នដែលអនុវត្ត រួមបញ្ចូលទាំងបណ្តាលក្ខខ័ណ្ឌទាក់ទងដល់ទណ្ឌកម្មអប្បបរិមានូវសេចក្តីត្រូវការសំរាប់ការធ្វើបត្យាប័ននិងកំណត់ហេតុដែលភាគីរដ្ឋដែលបានស្នើអាចបដិសេធការធ្វើបត្យាប័ន។

៨-ភាគីរដ្ឋទាំងឡាយត្រូវផ្អែកលើច្បាប់ស្រុករបស់ខ្លួន យកចិត្តទុកដាក់ដើម្បីធ្វើឱ្យបានរួសរាន់នូវនីតិវិធីបត្យាប័ន ហើយធ្វើឱ្យងាយស្រួលដល់សេចក្តីត្រូវការជាក់ស្តែងទាក់ទងដល់បទល្មើសទាំងឡាយណាដែលមាត្រានេះអនុវត្ត ។

៩-ផ្អែកលើបត្យាប័នរបស់ខ្លួនភាគីរដ្ឋដែលស្នើសុំ អាចទទួលយកដែលការធ្វើបត្យាប័នរបស់ជននោះត្រូវបានរកឃើញហើយជាអ្នកមានវត្តមានក្នុងដែនដីរបស់ខ្លួនក្នុងការឃុំឃាំង ឬទទួលយកបណ្តាវិធានការសមរម្យដទៃទៀតដើម្បីអះអាងធានាពីវត្តមានរបស់ខ្លួននូវនីតិវិធីបត្យាប័ននានា ផ្អែកលើភាពសមតាមបំណងដែលកាលៈទេសៈអនុញ្ញាតដូច្នេះ និងជាបន្ទាន់ហើយតាមសំណើរបស់ភាគីរដ្ឋដែលកំពុងស្នើសុំ ។

១០-ភាគីរដ្ឋមួយក្នុងដែនដីរបស់គេ ជនល្មើសដែលចោទប្រកាន់ត្រូវបានគេរកឃើញប្រសិនបើមិនធ្វើបត្យាប័នបុគ្គលនោះតាមរយៈបទល្មើសដែលមាត្រានេះអនុវត្តតែឯងលើបរិវេណដែលគាត់ ឬនាងជាជនមួយនៃជនជាតិខ្លួនតាមសំណើរឿងដោយគ្មានការពន្យាពេលជ្រុលហួសហេតុទៅអាជ្ញាធរមានសមត្ថកិច្ចទាំងឡាយរបស់ខ្លួនដើម្បីធ្វើការចោទប្រកាន់ ។ អាជ្ញាធរទាំងនោះត្រូវធ្វើសេចក្តីសំរេចរបស់ខ្លួននិងធ្វើកំណត់ហេតុរបស់ខ្លួនក្នុងលក្ខណៈ ដូចគ្នាដូចក្នុងករណីបទល្មើសដទៃទៀតនៃលក្ខណៈធ្ងន់ធ្ងរស្ថិតក្រោមច្បាប់ក្នុងស្រុករបស់ភាគីរដ្ឋនោះ បណ្តាភាគីរដ្ឋដែលពាក់ព័ន្ធត្រូវសហប្រតិបត្តិការជាមួយគ្នាជាពិសេសលើទស្សនៈវិស័យ និងជាក់ស្តែងដើម្បីធានាបានភាពគ្រប់គ្រាន់នៃការចោទប្រកាន់

១១-កាលណាភាគីរដ្ឋមួយត្រូវបានអនុញ្ញាតស្ថិតក្រោមច្បាប់ក្នុងស្រុករបស់ខ្លួន ដើម្បីធ្វើបត្យាប័ន ឬទោះបីជាជនសារភាពជាមនុស្សរបស់របស់ជាតិខ្លួនក៏ដោយ គ្រាន់តែផ្អែកលើលក្ខខ័ណ្ឌដែលបុគ្គលនេះ និងត្រូវបញ្ជូនត្រឡប់ទៅរដ្ឋនោះដើម្បីផ្តន្ទាទោស ដែលបានធ្វើជាលទ្ធផលនៃការជំនុំជំរះ ឬ នីតិវិធីនានាដើម្បីការធ្វើបត្យាប័ន

១២-ប្រសិនបើការធ្វើបត្យាប័នបានិរះរកបណ្តាគោលបំណង នៃការធ្វើឱ្យមានការផ្តន្ទាទោសត្រូវបានបដិសេធពីព្រោះបុគ្គលដែលបានិរះរកឃើញជាជនជាតិរបស់ភាគីរដ្ឋដែលស្នើសុំ ។ ភាគីរដ្ឋដែលបានស្នើសុំត្រូវពិចារណាការអនុវត្តន៍ ការផ្តន្ទាទោសដែលត្រូវបានធ្វើឡើងក្រោមច្បាប់ក្នុងស្រុករបស់ភាគីដែលកំពុងស្នើសុំ ឬច្បាប់ដែលមាននៅទីនោះប្រសិនបើច្បាប់ក្នុងស្រុករបស់ខ្លួនអនុញ្ញាតដូច្នេះហើយក្នុងអនុលោមភាពតាមសេចក្តីត្រូវការនៃច្បាប់នោះតាមការអនុវត្តន៍របស់ភាគីកំពុងស្នើសុំ ។

១៣-បុគ្គលណាមួយទាក់ទិនដល់នីតិវិធីកំពុងត្រូវបានដោះស្រាយ ទាក់ទងជាមួយបទល្មើសណាមួយដែលមាត្រានេះអនុវត្តត្រូវបានធានាដំណោះស្រាយយុត្តិធម៌ នៅគ្រប់ឱកាសនៃនីតិវិធីរួមទាំងការមានសិទ្ធិគ្រប់យ៉ាង និងការធានាទាំងឡាយបានផ្តល់ដោយច្បាប់ស្រុករបស់ភាគីរដ្ឋក្នុងទឹកដីដែលបុគ្គលនោះមានវត្តមាន ។

១៤-ប្រការដែលគ្មានក្នុងអនុសញ្ញានេះ ត្រូវបានបកស្រាយជាការដាក់កាតព្វកិច្ចដើម្បីធ្វើបត្យាប័នកាលណាភាគីរដ្ឋដែលបានស្នើសុំមានមូលហេតុដែលគួរឱ្យយកចិត្តទុកដាក់ដើម្បីឱ្យជឿថាសំណើត្រូវបានធ្វើឡើងដើម្បីគោលបំណងចោទប្រកាន់ ឬ ដាក់ទណ្ឌកម្មបុគ្គលម្នាក់ពីព្រោះភេទ ជាតិ សាសនា សញ្ជាតិ ទស្សនៈដើម ឬ នយោបាយរបស់បុគ្គលនោះ ឬដែលគោរពតាមសំណើរបណ្តាលឱ្យមានភាពលំអៀងដល់ស្ថានភាពរបស់បុគ្គលនោះចំពោះមូលហេតុណាមួយ ។

១៥-ភាគីរដ្ឋទាំងឡាយមិនអាចបដិសេធសំណើចំពោះការធ្វើបត្យាប័នពីមូលហេតុតែមួយដែលបទល្មើសត្រូវបានពិចារណាផងដែរដើម្បីដាក់ឱ្យពាក់ព័ន្ធបញ្ហាទាំងឡាយដែលផ្លាស់ប្តូរ ។

១៦-មុនពេលបដិសេធការធ្វើបត្យាប័ន ភាគីរដ្ឋដែលបានសំណូមពរត្រូវពិគ្រោះជាមួយភាគីរដ្ឋដែលកំពុងសំណើរដើម្បីផ្តល់វាតាមឱកាសគ្រប់គ្រាន់ ដើម្បីបង្ហាញទស្សនៈរបស់ខ្លួនហើយផ្តល់ពត៌មានពាក់ព័ន្ធដល់ការចោទប្រកាន់របស់ខ្លួនដែលត្រឹមត្រូវ ។

១៧-ភាគីរដ្ឋទាំងឡាយត្រូវរិះរកដើម្បីសន្និដ្ឋាន កិច្ចព្រមព្រៀងឬការចាត់ចែងរៀបចំជាទ្វេភាគី ឬ ពហុភាគីដើម្បីដោះស្រាយ ឬដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃការធ្វើបត្យាប័ន ។

## មាត្រាទី១៧

## ការបញ្ជូនអ្នកទោស

ភាគីរដ្ឋទាំងឡាយអាចពិចារណាការឈានចូលដល់ កិច្ចព្រមព្រៀងឬការចាត់ចែងជាទ្វេភាគី ឬពហុភាគីអំពីការផ្ទេរទឹកដីនៃជនដែលកាត់ទោសរួចដល់ការដាក់ពន្ធនាគារ ឬទំរង់ដទៃទៀតនៃការដកហូតសេរីភាពចំពោះបទល្មើសទាំងឡាយគ្របដណ្តប់ដោយអនុសញ្ញានេះដើម្បីពួកគេអាចបំពេញការផ្តន្ទាទោសរបស់គេនៅទីនោះ ។

## មាត្រាទី១៨

## ជំនួយផ្នែកច្បាប់ទៅវិញទៅមក

១-ភាគីរដ្ឋទាំងឡាយត្រូវទទួលយកមួយទៀតនូវវិធានការដ៏ទូលំទូលាយនៃជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងការស្រាវជ្រាវស៊ើបអង្កេត ការចោទប្រកាន់ និងនីតិវិធីយុត្តិធម៌ផ្សេងៗទាក់ទិនទៅ នឹងបណ្តាបទល្មើសគ្របដណ្តប់ដោយអនុសញ្ញាដូចបានចែងក្នុងមាត្រា ៣ ហើយត្រូវពង្រីកទៅវិញទៅមកនូវជំនួយប្រហែលគ្នាមួយទៀត ដែលភាគីរដ្ឋកំពុងស្នើសុំមានមូលហេតុសមរម្យ ដើម្បីការសង្ស័យថាបទល្មើស យោងក្នុងមាត្រា ៣ កថាខ័ណ្ឌ១ (a) ឬ (b) ជាលក្ខណៈឆ្លងដែនក្នុងនោះជនរងគ្រោះសាក្សី ប្រាក់កំរៃ ឯកសារច្បាប់ផ្សេងៗ ឬភស្តុតាងនៃបទល្មើសត្រូវបានគេដាក់ទីតាំងក្នុងភាគីរដ្ឋដែលបានស្នើសុំហើយដែលបទល្មើសទាក់ទិននឹងក្រុមឧក្រិដ្ឋជន ។

២-ជំនួយផ្នែកច្បាប់ទៅវិញទៅមកត្រូវបានទទួលយកនូវវិសាលភាពទាំងមូលដែលអាចធ្វើបានស្ថិតក្រោមច្បាប់ដែលពាក់ព័ន្ធសន្និសញ្ញា កិច្ចព្រមព្រៀង និងការចាត់ចែងរបស់ភាគីរដ្ឋដែលបានស្នើសុំចំពោះការស្រាវជ្រាវស៊ើបអង្កេតការចោទប្រកាន់ និងនីតិវិធីព្រហ្មទ័ណ្ឌ ពាក់ព័ន្ធទៅនឹងបទល្មើសនានា ចំពោះនីតិបុគ្គលអាចត្រូវបានទទួលខុសត្រូវអនុលោមតាមមាត្រាទី ១០ នៃអនុសញ្ញានេះក្នុងរដ្ឋដែលជាភាគីកំពុងស្នើសុំ ។

៣-ជំនួយផ្នែកច្បាប់ទៅវិញទៅមក ត្រូវបានទទួលយកអនុលោមតាមមាត្រានេះអាចត្រូវបានស្នើសុំ តាមបណ្តាគោលបំណងដូចខាងក្រោម :

a-ការទទួលយកភស្តុតាង ឬកំណត់ហេតុពីបុគ្គលនានា

b-ការផ្តល់ប្រសិទ្ធភាពនូវប្រព័ន្ធ ឯកសារតុលាការ

c-ការប្រតិបត្តិលើការស្រាវជ្រាវស៊ើបអង្កេត និងការរឹបអូស និងការដោះលែង

d-ការកំណត់កម្មវត្ថុ និងទីកន្លែង

e-ការផ្តល់ពត៌មានបទដ្ឋានជាភស្តុតាង និងការវាយតំលៃរបស់អ្នកជំនាញ

f-ការផ្តល់លក្ខណៈដើម ឬបញ្ជាក់ការថតចំលងឯកសារដែលពាក់ព័ន្ធនិងឯកសារ រួមបញ្ចូលទាំងរដ្ឋាភិបាល ធនាគារ ហិរញ្ញវត្ថុ សាជីវកម្ម ឬ ពាណិជ្ជកម្ម

g-ការបញ្ជាក់អិនភាគ ឬការបញ្ជាក់ស្លាកស្នាម កំរៃពីឧក្រិដ្ឋកម្ម កម្មសិទ្ធិ លិខិតករណ៍ ឬឯកសារផ្សេងៗ សំរាប់បណ្តាគោលបំណងជាតឹកតាង ។

h-ការសំរបសំរួល ការបង្ហាញខ្លួនដោយស្ម័គ្រចិត្ត នៃបុគ្គលទាំងឡាយក្នុងរដ្ឋជាភាគីដែលកំពុងស្នើសុំ

i-ជំនួយប្រភេទផ្សេងទៀតដែលមិនផ្ទុយទៅ និងច្បាប់ក្នុងស្រុករបស់ភាគីរដ្ឋដែលបានស្នើសុំ

៤-ដោយមិនប៉ះពាល់ដល់ច្បាប់ក្នុងស្រុក អាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីរដ្ឋមួយ អាចផ្សព្វផ្សាយពត៌មានពាក់ព័ន្ធបញ្ហាបទឧក្រិដ្ឋកម្ម ដោយគ្មានសំណើជាអាទិភាពចំពោះអាជ្ញាធរមានសមត្ថកិច្ចមួយ ក្នុងភាគីរដ្ឋមួយទៀតដែលពួកខ្លួនជឿថាពត៌មានទាំងនេះ អាចជួយអាជ្ញាធរក្នុងការប្រតិបត្តិ ឬការសម្រិទ្ធិផ្លដោយជោគជ័យការសាកសួរពត៌មាន និងកំណត់ហេតុបទឧក្រិដ្ឋកម្ម ឬអាចចេញលទ្ធផលក្នុងសំណើបានរៀបរាប់យ៉ាងច្បាស់លាស់ ដោយភាគីរដ្ឋបន្ទាប់តាមអនុសញ្ញានេះ ។

៥-ការបញ្ជូនពត៌មានទាក់ទងទៅនឹងកថាខ័ណ្ឌ ៤ នៃមាត្រានេះមិនត្រូវឱ្យប៉ះពាល់ការសាកសួរពត៌មានទាំងឡាយ និងនីតិព្រហ្មទណ្ឌនានាក្នុងរដ្ឋដែលអាជ្ញាធរមានសមត្ថកិច្ចកំពុងផ្តល់ពត៌មាន ។ អាជ្ញាធរមានសមត្ថកិច្ចនានាកំពុងទទួលពត៌មានត្រូវអនុលោមតាមសំណើរដែលពត៌មាន ដែលបានថែងនៅតែជាទំនុកចិត្តទោះជាបណ្តោះអាសន្ន ឬដោយការរឹតលើការប្រើប្រាស់របស់វាក៏ដោយ ។ ទោះបីជាបញ្ហានេះមិនបានទប់ស្កាត់ភាគីរដ្ឋដែលបានទទួលពីការលាតត្រដាងក្នុងកំណត់ហេតុពត៌មានថា ជាការឱ្យរួចទោសចំពោះជនដែលបានចោទប្រកាន់ក៏ដោយ ។ ក្នុងករណីដូចនេះភាគីរដ្ឋកំពុងទទួលត្រូវជូនពត៌មានដល់ភាគីរដ្ឋដែលកំពុងបញ្ជូនជាអាទិភាពចំពោះការលាតត្រដាងឱ្យដឹង និងប្រសិនបើបានស្នើដូចនេះត្រូវពិគ្រោះជាមួយភាគីរដ្ឋដែលកំពុងផ្ញើរ ។ ប្រសិនបើក្នុងករណីលើកលែងការសំគាល់ជាមុនមិនអាចធ្វើទៅបាន ភាគីរដ្ឋដែលកំពុងទទួលត្រូវជូនពត៌មានទៅភាគរដ្ឋ ដែលកំពុងផ្ញើរអំពីការលាតត្រដាងឱ្យដឹងដោយគ្មានការពន្យារពេលឡើយ ។

៦-បណ្តាបញ្ញត្តិនៃមាត្រានេះមិនត្រូវប៉ះពាល់កាតព្វកិច្ចនានា ស្ថិតក្រោមសន្ធិសញ្ញាដទៃទៀតជំនួយផ្នែកច្បាប់ទៅវិញទៅមកជាទ្វេភាគី ឬពហុភាគីដែលគ្រប់គ្រង ឬនឹងគ្រប់គ្រងទាំងមូល ឬជាផ្នែកៗ ។

៧-កថាខណ្ឌ ៩ ដល់ ២៩ នៃមាត្រានេះត្រូវអនុវត្តចំពោះសំណើរទាំងឡាយណាធ្វើឡើងទាក់ទងទៅនឹងមាត្រានេះកាលណាភាគីរដ្ឋដែលលើកឡើងមិនកំណត់ព្រំដែន ដោយសន្ធិសញ្ញាណាមួយនៃជំនួយផ្នែកច្បាប់ទៅវិញទៅមក ។ ប្រសិនបើភាគីរដ្ឋទាំងនោះត្រូវកំណត់ដោយសន្ធិសញ្ញាណាមួយ បទបញ្ញត្តិដែលស៊ីគ្នានៃសន្ធិសញ្ញានោះត្រូវអនុវត្តប្រសិនបើភាគីរដ្ឋនានាមិនយល់ព្រមអនុវត្តកថាខណ្ឌទាំងនេះ បើសិនណាពួកគេផ្តល់ភាពងាយស្រួលដល់កិច្ចសហប្រតិបត្តិការ ។

៨-ភាគីរដ្ឋទាំងឡាយមិនត្រូវបដិសេធ មិនផ្តល់នូវជំនួយផ្នែកច្បាប់ទៅវិញទៅមក ទាក់ទងនឹងមាត្រានេះអំពីមូលហេតុនៃការសំងាត់របស់ធនាគារឡើយ ។

៩-ភាគីរដ្ឋទាំងឡាយអាចបដិសេធមិនផ្តល់នូវជំនួយផ្នែកច្បាប់ទៅវិញទៅមកទាក់ទងទៅនឹងមាត្រានេះអំពីកង្វះខាតផ្នែកព្រហ្មទណ្ឌទាំងពីរទោះបីជាភាគីរដ្ឋដែលបានស្នើសុំ អាចផ្តល់ជំនួយកាលណាយល់ថាត្រឹមត្រូវសមរម្យចំពោះទំហំវាសំរេចនូវផ្តន្ទាសិទ្ធិដោយពុំគិតដល់ថាតើការប្រព្រឹត្ត និងបង្កើតបានជាបទល្មើសស្ថិតក្រោមច្បាប់ក្នុងស្រុករបស់ភាគីរដ្ឋស្នើរសុំក៏ដោយ ។

១០-បុគ្គលដែលកំពុងត្រូវបានឃុំគ្រង ឬកំពុងផ្តន្ទាទោសក្នុងទឹកដីរបស់ភាគីរដ្ឋមួយ ដែលខ្លួនមានវត្តមានក្នុងភាគីរដ្ឋមួយទៀតត្រូវបានស្នើសុំសំរាប់បណ្តាគោលបំណងនៃការផ្តល់អត្តសញ្ញាណសក្ខីភាព ឬផ្តល់ជំនួយក្នុងការទទួលភស្តុតាងដើម្បីធ្វើការអង្កេតការចោទប្រកាន់ឬកំណត់ហេតុព្រហ្មទ័ណ្ឌផ្សេងៗពាក់ព័ន្ធទៅនឹងបទល្មើសគ្របដណ្តប់ដោយអនុសញ្ញានេះអាចត្រូវបានផ្ទេរ ប្រសិនបើជួបបណ្តាលលក្ខខ័ណ្ឌខាងក្រោម :

a -បុគ្គលផ្តល់ការព្រមព្រៀងដែលបានរាយការណ៍ជូនរបស់ខព្រៀងដែលបានរាយការណ៍ជូនរបស់ខ្លួនដោយសេរី ។

b -អាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីរដ្ឋទាំងពីរព្រមព្រៀង ផ្អែកតាមបណ្តាលក្ខខ័ណ្ឌដូចភាគីរដ្ឋទាំងនោះអាចយល់ថាសមរម្យ

១១-ចំពោះបណ្តាគោលបំណងនៃកថាខ័ណ្ឌ ១០ នៃមាត្រានេះ :

a -ភាគីរដ្ឋដែលបុគ្គលត្រូវបានផ្ទេរត្រូវមានអំណាចនិងកាតព្វកិច្ចដើម្បីរក្សាទុកបុគ្គលដែលបានផ្ទេរស្ថិតក្នុងការឃុំគ្រងដរាបណាបានស្នើរ ឬ ដឹកនាំដោយភាគីរដ្ឋពីផ្អែកដែលបុគ្គលនេះត្រូវបានគេផ្ទេរមក ។

b -ភាគីរដ្ឋដែលបុគ្គលណាមួយត្រូវបានគេផ្ទេរឱ្យមិនត្រូវពន្យារនូវការអនុវត្តកាតព្វកិច្ចរបស់ខ្លួនដើម្បីបញ្ជូនត្រឡប់បុគ្គលចំពោះការឃុំគ្រង របស់ភាគីរដ្ឋពីផ្អែកដែលបុគ្គលដែលត្រូវបានផ្ទេរជាការព្រមព្រៀងជាមុន ឬជាកិច្ចព្រមព្រៀងដោយអាជ្ញាធរមានសមត្ថកិច្ច របស់ភាគីរដ្ឋទាំងពីរ ។

c -ភាគីរដ្ឋដែលបុគ្គលត្រូវបានផ្ទេរឱ្យមិនតំរូវឱ្យភាគីរដ្ឋនេះនូវអ្វីដែលបុគ្គលត្រូវបានគេផ្ទេរឱ្យដើម្បីផ្តើមនីតិបត្យាប័នសំរាប់ការបញ្ជូនមនុស្ស ។

d -បុគ្គលដែលបានផ្ទេរឱ្យត្រូវទទួលការគោរពចំពោះប្រព័ន្ធផ្តន្ទាទោសកំពុងប្រើប្រាស់ក្នុងរដ្ឋត្រង់ចំណុចដែលគាត់ ឬនាងត្រូវបានគេផ្ទេរសំរាប់រយៈពេលក្នុងការឃុំគ្រងរបស់ភាគីរដ្ឋ ដែលគាត់ត្រូវបានផ្ទេរឱ្យ ។

១២-ដរាបណាភាគីរដ្ឋត្រង់ចំណុចដែលបុគ្គលម្នាក់ ត្រូវបានគេផ្ទេរអនុលោមតាមកថាខ័ណ្ឌ ១០ និង ១១ នៃមាត្រានេះ ដូចនេះព្រមទទួលថាបុគ្គលនោះសញ្ជាតិរបស់គាត់មិនត្រូវបានចោទប្រកាន់ ឃុំខ្លួន ដាក់ទណ្ឌកម្ម ឬបាន ផ្អែកតាមការដាក់កំហិតផ្សេងទៀតចំពោះសេរីភាពផ្ទាល់ខ្លួនរបស់គាត់ក្នុងទឹកដីនៃរដ្ឋត្រង់ចំណុចបុគ្គលនោះត្រូវបាន បញ្ជូនផ្ទេរចំពោះការប្រព្រឹត្តការមិនបានធ្វើការកាត់ឱ្យជាប់ទោសជាអាទិ៍ដល់ការចាកចេញរបស់គាត់ពីទឹកដីរដ្ឋត្រង់ចំណុចដែលគាត់ត្រូវបានគេបញ្ជូនឱ្យ ។

១៣-ភាគីរដ្ឋនីមួយៗត្រូវចាត់តាំងអាជ្ញាធរកណ្ដាលមួយដែលមានការទទួលខុសត្រូវ និងអំណាចដើម្បីទទួលសំណើរចំពោះជំនួយផ្អែកច្បាប់ទៅវិញទៅមកហើយមួយណាក៏បានប្រហារជីវិតពួកគេ ឬបញ្ជូនពួកគេទៅអាជ្ញាធរនៃសមត្ថកិច្ចនានាដើម្បីធ្វើការប្រហារជីវិត ។ កន្លែងភាគីរដ្ឋមានតំបន់ពិសេស ឬទឹកដីដោយប្រព័ន្ធដោយឡែកនៃជំនួយផ្អែកច្បាប់ទៅវិញទៅមកភាគីរដ្ឋអាចចាត់តាំងអាជ្ញាធរកណ្ដាលផ្សេងដែលមាតួនាទីដូចគ្នាចំពោះតំបន់ ឬទឹក ដីនោះ ។ អាជ្ញាធរកណ្ដាលនានាត្រូវធានាអះអាងចំពោះល្បឿននិងការកាត់ទោសត្រឹមត្រូវ ឬការបញ្ជូននូវសំណើរដែលបានទទួល កន្លែងដែលអាជ្ញាធរកណ្ដាលបញ្ជូនសំណើរទៅអាជ្ញាធរមានសមត្ថកិច្ចចំពោះការកាត់ទោស ភាគីរដ្ឋត្រូវជំរុញការកាត់ទោសឱ្យបានលឿន និងត្រឹមត្រូវនៃសំណើរដោយអាជ្ញាធរមានសមត្ថកិច្ច ។ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវបានបំភ្លឺអំពីអាជ្ញាធរកណ្ដាលដែលបានចាត់តាំង ចំពោះគោលបំណងនេះទៅពេលភាគីរដ្ឋនីមួយៗដាក់បញ្ចូលការអនុម័ត ឬការឈានដល់អនុសញ្ញានេះរបស់ខ្លួនបណ្ដាសំណើរសំរាប់ជំនួយផ្អែកច្បាប់ទៅវិញទៅមកនិងការទំនាក់ទំនងនានាដែលពាក់ព័ន្ធត្រូវបានបញ្ជូនទៅអាជ្ញាធរកណ្ដាលនានា ដែលបានចាត់តាំងដោយភាគីរដ្ឋទាំងឡាយ ។ តំរូវការនេះមិនត្រូវប៉ះពាល់ដល់សិទ្ធិរបស់ភាគីរដ្ឋមួយដើម្បីតំរូវថាសំណើរនានានិងបណ្ដាការទំនាក់ទំនងត្រូវបានបញ្ជាក់ ដល់ភាគីរដ្ឋតាមស្ថានទូត ហើយក្នុងកាលៈទេសៈបន្ទាន់កន្លែងដែលភាគីរដ្ឋនានាយល់ព្រមតាមរយៈអង្គការនគរបាលព្រហ្មទណ្ឌអន្តរជាតិបើធ្វើទៅបាន ។

១៤-សំណើរទាំងអស់ត្រូវបានធ្វើឡើងដោយលាយល័ក្ខអក្សរដែលអាចធ្វើទៅបានតាមបណ្ដាមធ្យោបាយដែលអាចបង្កើតការចំលងជាលាយល័ក្ខអក្សរ ជាភាសាដែលអាចទទួលយកបានចំពោះភាគីរដ្ឋនោះ ដើម្បីបង្កើតភាពត្រឹមត្រូវអគ្គលេខាអង្គការសហប្រជាជាតិ ត្រូវបានផ្ដល់ពត៌មានអំពីភាសា ឬភាសានានាដែលអាចទទួលយកបានចំពោះភាគីរដ្ឋនីមួយៗនៅពេលដែលខ្លួនដាក់បញ្ចូលឯកសារនៃការឱ្យសច្ចានុម័តរបស់ខ្លួន ការទទួលយក ឬ ការព្រមព្រៀង ឬការឈានចូលដល់អនុសញ្ញានេះ ។ ក្នុងកាលៈទេសៈបន្ទាន់ហើយដែលបានយល់ព្រមដោយភាគីរដ្ឋទាំងឡាយ សំណើរនានាអាចត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ប៉ុន្តែត្រូវបានគេបញ្ជាក់អះអាងជាលាយល័ក្ខណ៏អក្សរជាបន្ទាន់ ។

១៥-សំណើរដើម្បីជំនួយផ្អែកច្បាប់ទៅវិញទៅមកត្រូវមាន :

a -អត្តសញ្ញាណរបស់អាជ្ញាធរដែលកំពុងធ្វើសំណើរ

b -បញ្ហាជាចំណង និងលក្ខណៈនៃការស៊ើបអង្កេតការចោទប្រកាន់ ឬនីតិវិធីយុត្តិធម៌

c -ការសង្ខេបនៃកំណត់ហេតុដែលពាក់ព័ន្ធ លើកលែងការពាក់ព័ន្ធទៅនឹងគោលបំណងនៃប្រព័ន្ធឯកសារយុត្តិធម៌

e -តាមដែលអាចធ្វើទៅបាន អត្តសញ្ញាណទីតាំង និងសញ្ជាតិ នៃបុគ្គលដែលពាក់ព័ន្ធ ។

f-គោលបំណងចំពោះភស្តុតាងពត៌មាន ឬ អំពើល្មើសត្រូវបានគេរកឃើញ ។

១៦-ភាគីរដ្ឋដែលបានស្នើសុំអាចស្នើពត៌មានបន្ថែម កាលណាវាមានការចាំបាច់សំរាប់ការបំពេញសំណើរ អនុលោមតាមច្បាប់ស្រុករបស់ខ្លួន ឬ កាលណាវាអាចសំរបសំរួលនូវការបំពេញនេះ ។

១៧-សំណើរត្រូវបានធ្វើឡើងអនុលោមតាមច្បាប់ស្រុករបស់ភាគីរដ្ឋដែលបានស្នើហើយចំពោះទំហំមិនផ្ទុយទៅនឹងច្បាប់ក្នុងស្រុករបស់ភាគីរដ្ឋដែលបានស្នើ ហើយដែលអាចធ្វើទៅបានអនុលោមតាមនីតិវិធីនានាបញ្ជាក់ក្នុងសំណើរ ។

១៨-តាមដែលអាចធ្វើទៅបានហើយស្របតាមគោលការណ៍ជាមូលដ្ឋាននៃច្បាប់ក្នុងស្រុកកាលណាបុគ្គលស្ថិតក្នុងទឹកដីរបស់ភាគីរដ្ឋមួយ ហើយត្រូវតែបានធ្វើជាសាក្សី ឬអ្នកជំនាញដោយអាជ្ញាធរតុលាការនៃភាគីរដ្ឋមួយទៀតភាគីរដ្ឋទី ១ អាចអនុញ្ញាតតាមសំណើរដទៃទៀត ដើម្បីធ្វើឡើងតាមរយៈសន្និសីទចាក់ផ្សាយតាមវីដេអូ ប្រសិនបើមិនអាចធ្វើទៅបាន ឬជាបំណងសំរាប់បុគ្គលជាប់ចោទដើម្បីបង្ហាញខ្លួនក្នុងទឹកដីរបស់ភាគីដែលកំពុងស្នើសុំ និងបានចូលរួមដោយអាជ្ញាធរតុលាការរបស់ភាគីរដ្ឋដែលបានស្នើសុំ ។

១៩-ភាគីរដ្ឋដែលកំពុងស្នើសុំមិនត្រូវផ្សព្វផ្សាយបញ្ជូន ឬប្រើប្រាស់ពត៌មាន ឬវត្ថុតាងបានផ្តល់ដោយភាគីរដ្ឋដែលបានស្នើឱ្យមានការស៊ើបអង្កេតការចោទប្រកាន់ ឬកំណត់ហេតុយុត្តិធម៌ ជាជាងបញ្ហាទាំងនោះបញ្ជាក់ក្នុងសំណើរដោយគ្មានការព្រមព្រៀងជាចំបង របស់ភាគីរដ្ឋដែលបានស្នើសុំ គ្មានចែងក្នុងកថាខ័ណ្ឌនេះទេត្រូវបានទប់ស្កាត់ភាគីដែលកំពុងស្នើសុំពីការលាតត្រដាងក្នុងកំណត់ហេតុនូវពត៌មាន ឬភស្តុតាងដែលជាការដាក់ទំងន់ដល់ជនជាប់ចោទក្នុងករណីបន្ទបន្ទាប់ភាគីរដ្ឋដែលកំពុងស្នើសុំត្រូវផ្តល់ពត៌មានឱ្យភាគីរដ្ឋដែលបានស្នើ សុំជាអាទិ៍ចំពោះការលាតត្រដាងនិងប្រសិនបើបានស្នើដូច្នេះ ពិគ្រោះយោបល់ជាមួយភាគីរដ្ឋដែលបានស្នើសុំ ។ ប្រសិនបើក្នុងករណីលើកលែងមួយកំណត់សំគាល់ជាមុនគឺមិនអាចធ្វើទៅបានភាគីរដ្ឋដែលកំពុងស្នើត្រូវជូនដំណឹងដល់ភាគីរដ្ឋ ដែលបានស្នើសុំនូវការលាតត្រដាងដោយមិនពន្យារពេល ។

២០-ភាគីរដ្ឋដែលកំពុងស្នើសុំអាចតំរូវការឱ្យភាគីរដ្ឋដែលបានស្នើសុំ រក្សាភាពជឿជាក់លើហេតុការណ៍និងភាពជាក់ស្តែងនៃសំណើរលើកលែងចំពោះភាពចាំបាច់ដើម្បីបំពេញសំណើរ ។ ប្រសិនបើភាគីរដ្ឋដែលបានស្នើសុំមិនអាចអនុលោមតាមសេចក្តីត្រូវការនៃភាពជឿជាក់វាត្រូវជូនដំណឹងដល់ភាគីរដ្ឋដែលកំពុងស្នើសុំ ។

២១-ជំនួយផ្នែកច្បាប់ទៅវិញទៅមកអាចត្រូវបានបដិសេធ

a-កាលណាសំណើរមិនត្រូវបានធ្វើឡើងអនុលោមតាមបញ្ញត្តិទាំងឡាយនៃមាត្រានេះ

b-កាលណាភាគីរដ្ឋដែលបានស្នើ ពិចារណាថាការបំពេញសំណើរគឺហាក់ដូចជាប៉ះពាល់អធិបតេយ្យភាពសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ឬអត្ថប្រយោជន៍សំខាន់ៗទៀត ។

c-កាលណាអាជ្ញាធរទាំងឡាយរបស់ភាគីរដ្ឋដែលបានស្នើត្រូវបានហាមឃាត់ ដោយច្បាប់ស្រុករបស់ខ្លួនពីការដោះស្រាយបទល្មើសដែលបានស្នើ ដោយផ្តោតទៅលើបទល្មើសស្រដៀងគ្នាវាផ្នែកលើការស៊ើបអង្កេតការចោទប្រកាន់ ឬកំណត់ហេតុតុលាការក្រោមវង្វង់យុត្តាធិការរបស់ ។

៦-កាលណាវាផ្ទុយទៅនឹងប្រព័ន្ធច្បាប់របស់ភាគីរដ្ឋដែលបានស្នើទាក់ទិនដល់ជំនួយ ផ្នែកច្បាប់ទៅវិញទៅមកចំពោះសំណើរដែលបានលើកឡើង ។

២២-ភាគីរដ្ឋទាំងឡាយមិនឱ្យបដិសេធសំណើរសំរាប់ជំនួយផ្នែកច្បាប់ទៅវិញទៅមក អំពីកំណត់ហេតុដែលបទល្មើសត្រូវបានពិចារណាផងដែរដើម្បីភ្ជាប់បញ្ហាផ្ទាសំប្តូរ ។

២៣-មូលហេតុទាំងឡាយត្រូវបានផ្តល់ឱ្យដើម្បីការបដិសេធជំនួយ ផ្នែកច្បាប់ទៅវិញទៅមក ។

២៤-ភាគីរដ្ឋដែលបានស្នើត្រូវបំពេញសំណើរដើម្បីជំនួយផ្នែកច្បាប់ទៅវិញទៅមក ឱ្យបានឆាប់តាមដែលអាចធ្វើទៅបានហើយត្រូវយកលក្ខណៈពេញលេញតាមដែលអាចធ្វើទៅបានអំពីបញ្ហាទាល់ច្រកបានពិចារណាដោយភាគីរដ្ឋដែលកំពុងស្នើនិងដើម្បីមូលហេតុណាដែលគេផ្តល់ឱ្យផ្តោតក្នុងសំណើរ ។ ភាគីរដ្ឋដែលបានស្នើសុំត្រូវឆ្លើយតបទៅនឹងសំណើរដោយសមរម្យដោយភាគីរដ្ឋដែលកំពុងស្នើសុំអំពីភាពរីកចំរើន នៃការដោះស្រាយរបស់ខ្លួននៃសំណើរភាគីរដ្ឋដែលកំពុងស្នើសុំត្រូវជូនដំណឹងត្រឹមត្រូវដល់ភាគីរដ្ឋដែលបានស្នើកាលណាជំនួយបានរកឃើញគឺត្រូវបានតំរូវយូរអង្វែង ។

២៥-ជំនួយផ្នែច្បាប់ទៅវិញទៅមកអាចត្រូវបានពន្យារពេលដោយភាគីរដ្ឋដែលបានស្នើអំពីមូលហេតុដែលវាជ្រៀតជ្រែកដោយការស៊ើបអង្កេតដែលកំពុងបន្តការចោទប្រកាន់ ឬនីតិតុលាការ ។

២៦-មុនពេលបដិសេធសំណើរមួយស្របតាមកឋាខ័ណ្ឌ ២១ នៃមាត្រានេះ ឬពន្យាពេលការបញ្ចប់របស់ខ្លួនស្របតាមកឋាខ័ណ្ឌ ២៥ នៃមាត្រានេះភាគីរដ្ឋដែលបានស្នើសុំត្រូវពិគ្រោះជាភាគីរដ្ឋដែលកំពុងស្នើសុំដើម្បីពិចារណាថាតើជំនួយអាចត្រូវបានលើកឡើងផ្អែកតាមវាក្យស័ព្ទ និងលក្ខខ័ណ្ឌនានាកាលណាយល់ថាចាំបាច់ ។ ប្រសិនបើភាគីរដ្ឋកំពុងស្នើសុំទទួលយកជំនួយផ្អែកតាមលក្ខខ័ណ្ឌទាំងនោះខ្លួនត្រូវអនុលោមតាមលក្ខខ័ណ្ឌទាំងនេះ ។

២៧-ដោយមិនប៉ះពាល់ដល់ការអនុវត្តនឹកឋាខ័ណ្ឌ ១២ នៃមាត្រានេះសាក្សីម្នាក់អ្នកឯកទេស ឬបុគ្គលដទៃទៀតដែលជាអ្នកតាមសំណើរនៃភាគីរដ្ឋកំពុងស្នើសុំ ភាពព្រមព្រៀងផ្តល់វត្តមានក្នុងកំណត់ហេតុ ឬជួយក្នុងការស៊ើបអង្កេតការចោទប្រកាន់ឬនីតិវិធីតុលាការក្នុងដែនដីរបស់ភាគីរដ្ឋដែលកំពុងស្នើសុំមិនត្រូវបានចោទប្រកាន់ ឃុំឃាំងដាក់ទណ្ឌកម្ម ឬបានផ្អែកតាមការដោក់កំរិតផ្សេងៗចំពោះសេរីភាពផ្ទាល់ខ្លួនរបស់គាត់ ឬ នាង ក្នុងដែនដីនេះដែលបានប្រព្រឹត្តបទល្មើស ។ ការលុបចោល ឬការផ្តន្ទាទោសជាអាទិភាពចំពោះការចាកចេញរបស់គាត់ ឬនាង ពីដែនដីរបស់ភាគីរដ្ឋដែលបានស្នើ ។ ការផ្តល់សុវត្ថិភាពដូច្នេះត្រូវបញ្ឈប់កាលណាសាក្សីអ្នកឯកទេស ឬ បុគ្គលដទៃទៀតកំពុងមានរយៈពេល១៥ថ្ងៃ ឬរយៈពេលផ្សេងពីនេះបានព្រមព្រៀងដោយភាគីរដ្ឋទាំងឡាយ ចាប់ពីថ្ងៃដែលគាត់ ឬ នាង ត្រូវបានជូនដំណឹងជាផ្លូវការថាវត្តមានរបស់គាត់ ឬ នាងគឺមិនយូរបានតំរូវដោយអាជ្ញាធរតុលាការទាំងឡាយ ឱកាសនៃការចាកចេញទោះជាមានដោយសេរីក្នុងដែនដីរបស់ភាគីរដ្ឋដែលកំពុងស្នើសុំ ឬបានទុកវាបានទទួលមកវិញនូវឆន្ទៈដោយសេរីរបស់ខ្លួនគាត់ ឬ នាង ។

២៨-តម្លៃទាំងឡាយជាធម្មតា នៃការបំពេញសំណើរត្រូវបានកំទេចចោលដោយភាគីរដ្ឋដែលបានស្នើសុំដរាបណាបានយល់ព្រមដោយភាគីរដ្ឋទាំងឡាយដែលពាក់ព័ន្ធ ។ ប្រសិនបើការចំណាយនៃលក្ខណៈគ្រប់គ្រាន់ ឬវិសាមញ្ញគឺ ឬ និងត្រូវបានតម្រូវដើម្បីបំពេញសំណើរភាគីរដ្ឋនានា ។

២៩-ភាគីរដ្ឋដែលបានស្នើសុំ

ឌ-ត្រូវផ្តល់ឱ្យភាគីរដ្ឋដែលកំពុងស្នើសុំនូវការថតចំលង ការកត់ត្រាទាំងឡាយរបស់រដ្ឋាភិបាល ឯកសារនានាឬពត៌មានដែលជាកម្មសិទ្ធិរបស់ខ្លួនដែលស្ថិតក្រោមច្បាប់ក្នុងស្រុករបស់ខ្លួនមានសុពលភាពដល់សាធារណៈជាទូទៅ។

ខ-អាចតាមឆន្ទានុសិទ្ធិរបស់ខ្លួនផ្តល់ឱ្យ ភាគីរដ្ឋដែលកំពុងស្នើសុំទាំងមូលជាផ្នែក ឬ ផ្នែកតាមលក្ខខ័ណ្ឌទាំងនេះដូចដែលយល់ថាសមរម្យការចម្លងឯកសាររដ្ឋាភិបាលផ្សេងៗ ឯកសារនានា ឬពត៌មានជាកម្មសិទ្ធិរបស់ខ្លួនដែលស្ថិតក្រោមច្បាប់ស្រុករបស់ខ្លួន គឺមិនមានសុពលភាពដល់សាធារណៈជាទូទៅ ។

៣០-ភាគីរដ្ឋទាំងឡាយត្រូវពិចារណាតាមដែលអាចចាំបាច់ លទ្ធភាពនៃការសន្និដ្ឋាន សេចក្តីព្រមព្រៀង ឬការរៀបចំជាទ្វេភាគីឬពហុភាគីដែលបំរើឱ្យបណ្តាគោលបំណងផ្តល់ប្រសិទ្ធិភាពដែលអនុវត្ត ឬពង្រឹងបញ្ញត្តិទាំងឡាយនៃមាត្រានេះ ។

## មាត្រា១៩

## ការស៊ើបអង្កេតរួម

ភាគីរដ្ឋទាំងឡាយត្រូវពិចារណាលើការសន្និដ្ឋានអំពីកិច្ចព្រមព្រៀង ឬការរៀបចំជាទ្វេភាគី ឬ ពហុភាគីដោយធ្វើឱ្យការទាក់ទងដល់បណ្តាបញ្ហាដែលជាប្រធានបទនៃការស៊ើបអង្កេតការចោទប្រកាន់នីតិវិធីតុលាការក្នុងរដ្ឋមួយឬរដ្ឋច្រើនអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធអាចបង្កើតស្ថាប័នស៊ើបអង្កេតរួមនានា ។ ក្នុងករណីពាត់បង់កិច្ចព្រមព្រៀង ឬការរៀបចំការស៊ើបអង្កេតរួមចំរុះអាចបានធ្វើឡើងដោយកិច្ចព្រមព្រៀងអំពីករណីដោយករណីទៀងទាត់ ភាគីរដ្ឋទាំង-ឡាយដែលពាក់ព័ន្ធត្រូវធានាអះអាងថាអធិបតេយ្យភាពរបស់ភាគីរដ្ឋក្នុងដែនដីដែលការស៊ើបអង្កេតគឺដើម្បីអនុវត្តត្រូវបានគោរពដោយពេញលេញ ។

## មាត្រា២០

## ទេពកោសល្យ នៃការស៊ើបអង្កេតពិសេស

១-ប្រសិនបើបានអនុញ្ញាតដោយគោលការណ៍គ្រឹះ នៃប្រព័ន្ធច្បាប់ស្រុករបស់ខ្លួនភាគីរដ្ឋនីមួយៗត្រូវតាមលទ្ធភាពរបស់ខ្លួនចាត់វិធានការចាំបាច់ដើម្បីអនុញ្ញាតឱ្យការប្រើប្រាស់ត្រឹមត្រូវ នៃការរកឃើញដែលបានត្រួតត្រាកាន់កាប់ហើយខ្លួនយល់ថាសមរម្យ ចំពោះការប្រើប្រាស់ទេពកោសល្យនៃការស៊ើបអង្កេត និងការប្រតិបត្តិជាសំងាត់ដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនក្នុងដែនដីខ្លួនចំពោះគោលបំណងនៃការប្រយុទ្ធប្រឆាំង នឹងឧក្រិដ្ឋកម្មដែលបានរៀបចំឱ្យមានប្រសិទ្ធិភាព ។

២-ចំពោះគោលបំណងនៃការស៊ើបអង្កេតបណ្តាបទល្មើសគ្របដណ្តប់ដោយអនុសញ្ញានេះភាគីរដ្ឋទាំង-ឡាយត្រូវបានជំរុញ ដើម្បីសន្និដ្ឋានកាលណាចាំបាច់កិច្ចព្រមព្រៀងឬការរៀបចំជាទ្វេភាគីដែលសមរម្យចំពោះការប្រើ-ប្រាស់ទេពកោសល្យស៊ើបអង្កេតពិសេសក្នុងបរិបទនៃកិច្ចសហប្រតិបត្តិការនៅថ្នាក់អន្តរជាតិ ។ កិច្ចព្រមព្រៀង ឬការរៀបចំទាំងនេះត្រូវបានសន្និដ្ឋាន និងអនុវត្តដោយពេញលេញអនុលោមតាមគោលការណ៍ស្មើភាពជាអធិបតេយ្យភាពរបស់រដ្ឋទាំងឡាយ និងត្រូវបានដោះស្រាយយ៉ាងម៉ត់ចត់ស្របតាមវាក្យស័ព្ទនៃកិច្ចព្រមព្រៀងឬការរៀបចំទាំងនោះ ។

៣-ក្នុងករណីបាត់កិច្ចព្រមព្រៀង ឬការរៀបចំដូចចែងក្នុងកឋាខ័ណ្ឌ ២ នៃមាត្រានេះនៅថ្នាក់អន្តរជាតិ ត្រូវបានធ្វើឡើងជាទៀងទាត់ហើយអាចកាលណាចាំបាច់ដាក់ឱ្យពិចារណាកិច្ចព្រមព្រៀង និងការយល់ដឹងផ្នែកហិរញ្ញ-វត្ថុចំពោះការអនុវត្តន៍យុត្តាធិការដោយភាគីរដ្ឋទាំងឡាយដែលពាក់ព័ន្ធ ។

៤-សេចក្តីសំរេចឱ្យប្រើប្រាស់ការរកឃើញដែលកាន់កាប់នៅថ្នាក់អន្តរជាតិអាចតាមការស្ម័គ្រចិត្តពីភាគីរដ្ឋដែលពាក់ព័ន្ធរួមមានមេរៀនដូចជាការស្ទាក់ចាប់ និងការអនុញ្ញាតឱ្យទំនិញបន្ត ឬត្រូវបានផ្លាស់ចេញទាំងមូលឬជាផ្នែកៗ

## មាត្រាទី២១

## ការផ្ទេរកំណត់ហេតុព្រហ្មទណ្ឌ

ភាគីរដ្ឋទាំងឡាយត្រូវពិចារណាអំពីលទ្ធភាពនៃការផ្ទេរកំណត់ហេតុពីមួយទៅមួយទៀត ដើម្បីចោទប្រកាន់អំពីបទល្មើសគ្របដណ្តប់ដោយអនុសញ្ញានេះក្នុងករណីផ្សេងៗ ដែលការផ្ទេរទាំងនេះត្រូវបានពិចារណាជាសារៈប្រយោជន៍នៃស្ថាប័នតុលាការត្រឹមត្រូវក្នុងករណីពិសេសដែលយុត្តាធិការពីរ ឬ គឺបានពាក់ព័ន្ធតាមទស្សនៈចំពោះការយកចិត្តទុកដាក់លើការចោទប្រកាន់ ។

## មាត្រាទី២២

## ការបង្កើតអត្ថបទព្រហ្មទណ្ឌ

ភាគីរដ្ឋនីមួយៗអាចអនុវត្តបទបញ្ញត្តិ ឬវិធានការផ្សេងជាចាំបាច់ដើម្បីពិចារណាក្រោមវាក្យស័ព្ទដូចនេះហើយដើម្បីគោលបំណងដែលខ្លួនយល់ថាសមរម្យការផ្តន្ទាទោសមុនក្នុងរដ្ឋមួយទៀតនៃជនជាប់ចោទតាមគោលបំណងនៃការប្រើប្រាស់ពត៌មានក្នុងកំណត់ហេតុព្រហ្មទណ្ឌទាក់ទងដល់បទល្មើសគ្របដណ្តប់ដោយអនុសញ្ញានេះ ។

## មាត្រាទី២៣

## ការចាត់ជាបទព្រហ្មទណ្ឌនៃការរារាំងយុត្តិធម៌

ភាគីរដ្ឋនីមួយៗត្រូវអនុវត្តបទបញ្ញត្តិនិងវិធានការផ្សេងជាចាំបាច់ ដើម្បីបង្កើតបទព្រហ្មទណ្ឌកាលណាបានប្រព្រឹត្តដោយចេតនា :

a-ការប្រើប្រាស់កំលាំងកាយ ការគំរាមគំហែង ឬការបំភិតបំភ័យ ឬការសន្យា ការផ្តល់ឱ្យ ឬការឱ្យនូវអត្ថប្រយោជន៍ហួសហេតុដើម្បីទាក់ទាញជំរុញឱ្យខុសសក្ខីភាព ឬក្នុងការជ្រៀតជ្រែកក្នុងកិច្ចការបទល្មើសបានគ្របដែលដណ្តប់ដោយអនុសញ្ញានេះ ។

b-ការប្រើប្រាស់កំលាំងកាយ ការគំរាមគំហែង ឬការបំភិតបំភ័យ ដើម្បីជ្រៀតជ្រែកតាមការអនុវត្តភារៈកិច្ចជាផ្លូវការដោយមន្ត្រីតុលាការ ឬមន្ត្រីប្រតិបត្តិច្បាប់ទាក់ទងដល់ការប្រព្រឹត្តបទល្មើសគ្របដណ្តប់ដោយអនុសញ្ញានេះ ។ ការមិនមានក្នុងកឋាខ័ណ្ឌត្រូវលំអៀងចំពោះសិទ្ធិរបស់ភាគីរដ្ឋទាំងឡាយដល់បទបញ្ញត្តិដែលការពារក្រុមផ្សេងៗនៃមន្ត្រីសាធារណៈ ។

## មាត្រានី២៤
## ការការពារសាក្សី

១-រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការសមស្របតាមមធ្យោបាយរបស់ខ្លួនដើម្បីផ្តល់ការការពារដែលមានប្រសិទ្ធិភាពអោយរួចផុតពីការសងសឹកខ្លានុពល ឬការបំភិតបំភ័យសាក្សី ក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌដែលផ្តល់កសិណសាក្សីទាក់ទិននឹងបទល្មើសដែលមានចែងក្នុងអនុសញ្ញានេះ និងកិច្ចការពារចំពោះសាច់ញាតិ ឬ បុគ្គលផ្សេងទៀតដែលជិតស្និទ្ធនឹងសាក្សី ។

២-វិធានការដែលមានចែងក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះអាចរាប់បញ្ចូលទាំងសិទ្ធិទាំងឡាយដែលមិនប៉ះពាល់ដល់សិទ្ធិរបស់ចុងចម្លើយ ដូចជាសិទ្ធិទទួលដំណើរការក្តីត្រឹមត្រូវ :

ក-ការបង្កើតនីតិវិធីដើម្បីការពាររាងកាយបុគ្គលទាំងនោះក្នុងកំរិតដែលចាំបាច់ នឹងអាចធ្វើទៅបានដូចជាការដាក់អោយកន្លែងដើម និងអនុញ្ញាតការមិនលាតត្រដាងពិតមាន ឬកំរិតលើការលាតត្រដាងពិតមានទាក់ទិននឹងអត្តសញ្ញាណ និងទីកន្លែងរបស់បុគ្គលទាំងនោះ ។

ខ-កំណត់នូវវិធានភស្តុតាងដើម្បីអនុញ្ញាតអោយសាក្សីផ្តល់ភស្តុតាង តាមរបៀបមួយដែលធានាដល់សុវត្ថិភាពរបស់សាក្សី ដូចជាការអនុញ្ញាតអោយផ្តល់ភស្តុតាងតាមការប្រើបច្ចេកវិទ្យាទំនាក់ទំនង ដូចជាបណ្តាញវីដេអូ ឬមធ្យោបាយផ្សេងទៀត ។

៣-រដ្ឋភាគីទាំងឡាយត្រូវពិចារណាចុះកិច្ចព្រមព្រៀងនានា ឬចំណាត់ការជាមួយរដ្ឋផ្សេងទៀតដើម្បីដាក់អោយបុគ្គលទាំងនោះដើម្បីអោយទៅកន្លែងដើមវិញ ដូចមានចែងក្នុងវាក្យខ័ណ្ឌទី២ខាងលើនេះ ។

៤-បទប្បញ្ញត្តិនេះត្រូវអនុវត្តផងដែរចំពោះជនរងគ្រោះដែលធ្វើជាសាក្សី ។

## មាត្រានី២៥
## ការផ្តល់ជំនួយ និងការការពារជនរងគ្រោះ

១-រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការសមស្របតាមមធ្យោបាយរបស់ខ្លួនដើម្បីផ្តល់ជំនួយដល់ជនរងគ្រោះពីបទល្មើសដែលមានចែងក្នុងអនុសញ្ញានេះ ជាពិសេសក្នុងករណីមានការគំរាមកំហែងសងសឹក ឬការបំភិតបំភ័យ ។

២-រដ្ឋភាគីនីមួយៗត្រូវបង្កើតនីតិវិធីសមស្របដើម្បីផ្តល់លទ្ធភាពអោយជនរងគ្រោះអាចទារសំណង ឬបដិទានបទល្មើសដែលមានចែងក្នុងអនុសញ្ញានេះ ។

៣-អនុលោមតាមច្បាប់ជាតិរបស់ខ្លួន រដ្ឋភាគីនីមួយៗត្រូវផ្តល់លទ្ធភាពអោយជនរងគ្រោះអាចសំដែងទស្សនៈ និងការព្រួយបារម្ភ ហើយត្រូវពិចារណាតាមដំណាក់កាលសមស្របនៃដំណើរការក្តីព្រហ្មទណ្ឌប្រឆាំងនឹងជនល្មើសតាមរបៀបដែលមិនប៉ះពាល់ដល់សិទ្ធិរបស់ចុងចម្លើយឡើយ ។

## មាត្រាទី២៦

## វិធានការពង្រឹងសហប្រតិបត្តិការជាមួយមន្ត្រីអនុវត្តន៍ច្បាប់

១-រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការសមស្រប ដើម្បីជំរុញអោយបុគ្គលដែលចូលរួមក្នុងឬបានចូលរួមក្នុងក្រុមឧក្រិដ្ឋកម្មរៀបចំ :

ក-ផ្តល់ព័តមានដែលមានប្រយោជន៍ចំពោះអាជ្ញាធរមានសមត្ថកិច្ច សំរាប់គោលបំណងស៊ើបអង្កេត ឬភ័ស្តុតាងក្នុងបញ្ហាទាំងនោះដូចជា :

I-អត្តសញ្ញាណ លក្ខណៈ សមត្ថភាព រចនាសម្ព័ន្ធ ទីតាំង ឬសកម្មភាពនៃក្រុមឧក្រិដ្ឋកម្មរៀបចំ

II-ទំនាក់ទំនងជាមួយក្រុមឧក្រិដ្ឋកម្មរៀបចំដទៃទៀតជាអាទិ៍មានទំនាក់ទំនងអន្តរជាតិ ។

III-បទល្មើសដែលក្រុមឧក្រិដ្ឋកម្មរៀបចំបានប្រព្រឹត្ត ឬអាចនឹងប្រព្រឹត្ត ។

ខ-ផ្តល់ជំនួយប្រយោល ឬដោយផ្ទាល់ដល់អាជ្ញាធរមានសមត្ថកិច្ចដែលអាចឈានទៅដល់ការកាត់ផ្តាច់ប្រភពធនធាន ឬការបន្តបទល្មើសរបស់ក្រុមឧក្រិដ្ឋកម្មរៀបចំ ។

២-រដ្ឋភាគីនីមួយៗត្រូវតែពិចារណាផ្តល់លទ្ធភាពនូវស្ថានសំរាលទោសជនជាប់សង្ស័យក្នុងករណីសមស្រប បើជននោះបានផ្តល់កិច្ចសហការច្រើនក្នុងការស៊ើបអង្កេត ឬការចោទប្រកាន់ពីបទល្មើសដែលមានចែងក្នុងអនុសញ្ញានេះ ។

៣-អនុលោមតាមគោលការណ៍ច្បាប់មូលដ្ឋានរបស់ខ្លួនរដ្ឋភាគីនីមួយៗត្រូវតែពិចារណាផ្តល់នូវបុព្វសិទ្ធិរួចផុតពីក្នុងករណីសមស្របបើជននោះបានផ្តល់កិច្ចសហការច្រើនក្នុងការស៊ើបអង្កេត ឬការចោទប្រកាន់ពីបទល្មើសដែលមានចែងក្នុងអនុសញ្ញានេះ ។

៤-ការការពារជនទាំងនោះ ត្រូវធ្វើឡើងស្របតាមមាត្រា ២៤ នៃអនុសញ្ញានេះ ។

៥-កាលណាជនដែលចែងយោងក្នុងវាក្យខ័ណ្ឌទី១ នៃមាត្រានេះ ស្ថិតនៅក្នុងរដ្ឋភាគីមួយ រដ្ឋនេះត្រូវផ្តល់កិច្ចសហការអោយបានគ្រប់គ្រាន់ដល់អាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីមួយទៀត រដ្ឋភាគីដែលពាក់ព័ន្ធអាចពិចារណាធ្វើកិច្ចព្រមព្រៀង ឬចំណាត់ការនានាអនុលោមទៅតាមច្បាប់ជាតិរបស់ខ្លួនដែលទាក់ទងការផ្តល់នូវប្រព្រឹត្តិកម្មដោយរដ្ឋភាគីឯទៀតដូចមានចែងក្នុងវាក្យខ័ណ្ឌទី២ និង ទី៣ នៃមាត្រានេះ ។

## មាត្រានី២៧

## កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់

១-ភាគីរដ្ឋទាំងឡាយត្រូវសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយ ភាគីរដ្ឋមួយទៀតស្របតាមប្រព័ន្ធច្បាប់ស្រុក និងប្រព័ន្ធរដ្ឋបាលរបស់ខ្លួនជំរុញប្រសិទ្ធភាពនៃការអនុវត្តន៍ច្បាប់ ដើម្បីទប់ស្កាត់បណ្តាបទល្មើសគ្របដណ្តប់ដោយអនុ-សញ្ញានេះ ជាពិសេសភាគីរដ្ឋនីមួយៗត្រូវអនុវត្តបណ្តាវិធានការដ៏មានប្រសិទ្ធភាព :

a-ត្រូវជំរុញ ហើយដែលចាំបាច់ដើម្បីបង្កើតទំនាក់ទំនងរវាងអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនទីភ្នាក់ងារ និងសេវានានាដើម្បីសំរបសំរួលសន្តិសុខ និងការផ្លាស់ប្តូរពត៌មានបន្ទាន់ពាក់ព័ន្ធកត្តាទាំងអស់នៃបទល្មើស គ្របដណ្តប់ដោយអនុសញ្ញានេះរួមមាន ប្រសិនបើភាគីរដ្ឋទាំងអស់ដែលពាក់ព័ន្ធយល់ថាសមរម្យភ្ជាប់សកម្មភាពបទល្មើស ផ្សេងៗ ។

b-ដើម្បីសហប្រតិបត្តិការជាមួយភាគីរដ្ឋដទៃទៀត ក្នុងការសាកសួរពត៌មានចំពោះបណ្តាបទល្មើសបានគ្របដណ្តប់ដោយសួរពត៌មានចំពោះបណ្តាបទល្មើសបានគ្របដណ្តប់ដោយអនុសញ្ញានេះពាក់ព័ន្ធនឹង :

( i )-អត្តសញ្ញាណ កន្លែងណានិងសកម្មភាព របស់ជនដែលបានសង្ស័យនូវការពាក់ព័ន្ធនឹងបទល្មើស ឬទីតាំងនៃជនដែលពាក់ព័ន្ធ ។

( ii )-បំលាស់ប្តូរកំរៃពីបទល្មើស ឬកម្មសិទ្ធិបានមកពីការប្រព្រឹត្តបទល្មើស

( iii )-បំលាស់ប្តូរកម្មសិទ្ធ បរិក្ខារ ឬលិខិតករណ៍ផ្សេងៗបានប្រើប្រាស់ ឬបានមានចេតនាដើម្បីប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ។

( c )-ផ្តល់នៅពេលត្រឹមត្រូវ បញ្ហាចាំបាច់ ឬបរិមាណចាំបាច់នៃផ្នែកសំខាន់ៗសំរាប់បំណងវិភាគឬបំណងស៊ើបអង្កេត ។

( d )-សំរបសំរួលឱ្យមានប្រសិទ្ធភាពរវាងអាជ្ញាធរមានសមត្ថកិច្ចរបស់ផងខ្លួន ភ្នាក់ងារ និងសេវាកម្មផ្សេងៗ ហើយជំរុញការផ្លាស់ប្តូរបុគ្គលិក និងអ្នកជំនាញការផ្សេងៗទៀតការដាក់បញ្ចូលផ្នែកតាមការរៀបចំ ឬកិច្ចព្រមព្រៀងជាទ្វេភាគីរវាងភាគីរដ្ឋពាក់ព័ន្ធ ការផ្តល់តួនាទីមន្ត្រីទំនាក់ទំនង ។

(e )-ផ្លាស់ប្តូរពត៌មានជាមួយភាគីរដ្ឋដទៃទៀតតាមមធ្យោបាយជាក់ស្តែង និងមេរៀនជាក់ស្តែងបានអនុវត្តដោយក្រុមឧក្រិដ្ឋជន ការដាក់បញ្ចូលដែលអាចអនុវត្តបានតាមផ្លូវ និងការដឹកនាំទំនិញ និងការប្រើប្រាស់អត្តសញ្ញាណខុសកែប្រែ ឬធ្វើឱ្យខុសឯកសារ ឬមធ្យោបាយផ្សេងៗនៃការលុបចោលសកម្មភាពរបស់ពួកខ្លួន ។

(៩)-ផ្លាស់ប្តូរពត៌មាន និងសំរបសំរួលវិធានការផ្តើមចាលនិងវិធានការផ្សេងៗដែលបានអនុវត្តត្រឹមត្រូវចំពោះគោលបំណងនៃការបញ្ជាក់បទល្មើសជាមុនបានគ្របដណ្តប់ដោយអនុសញ្ញានេះ ។

២-តាមទស្សនៈចំពោះការផ្តល់ប្រសិទ្ធភាពដល់អនុសញ្ញានេះ ភាគីរដ្ឋទាំងឡាយត្រូវពិចារណាការចូលដល់កិច្ចព្រមព្រៀង ឬការរៀបចំជាទ្វេភាគី ឬពហុភាគីអំពីការដឹកនាំកិច្ចសហប្រតិបត្តិការដោយផ្ទាល់ដោយភ្នាក់ងារប្រតិបត្តិច្បាប់របស់ខ្លួនហើយដែលកិច្ចព្រមព្រៀង ឬការរៀបចំទាំងនេះមានរួចហើយការធ្វើវិសោធនកម្មវា ។ ក្នុងករណីបាត់បង់កិច្ចព្រមព្រៀង ឬការរៀបចំរវាងភាគីរដ្ឋដែលពាក់ព័ន្ធ ភាគីទាំងនោះត្រូវពិចារណាអនុសញ្ញានេះ ។ ជាពេលត្រឹមត្រូវភាគីរដ្ឋទាំងឡាយត្រូវអនុវត្តដោយពេញលេញនូវការអនុវត្តកិច្ចព្រមព្រៀង ឬការរៀបចំរួមបញ្ចូលអង្គការអន្តរជាតិ អង្គការក្នុងតំបន់ដើម្បីជំរុញកិច្ចសហប្រតិបត្តិការរវាងទីភ្នាក់ងារអនុវត្តច្បាប់របស់ខ្លួន ។

៣-ភាគីរដ្ឋទាំងឡាយត្រូវយកចិត្តទុកដាក់សហប្រតិបត្តិការតាមមធ្យោបាយរបស់ខ្លួនដើម្បីឆ្លើយតបទៅនឹងបទឧក្រិដ្ឋកម្មឆ្លងដែនដែលបានប្រព្រឹត្តតាមរយៈការប្រើប្រាស់បច្ចេកទេសវិជ្ជាទំនើប ។

## មាត្រានី២៨

## ការប្រមូលផ្តុំ ការផ្លាស់ប្តូរ ការវិភាគពត៌មាន អំពីលក្ខណៈបទឧក្រិដ្ឋកម្មដែលបានរៀបចំ

១-ភាគីរដ្ឋនីមួយៗត្រូវពិចារណាលើការវិភាគ ក្នុងការពិគ្រោះយោបល់ជាមួយសហគមន៍ដែលមានទេពកោសល្យ ឬសហគមន៍ដែលមានការសិក្សា និន្នាការក្នុងបទឧក្រិដ្ឋក្នុងដែនដីរបស់ខ្លួនស្ថានការដែលបទឧក្រិដ្ឋកើតឡើងក៏ដូចជាក្រុមជំនាញ និងបច្ចេកវិជ្ជាដែលពាក់ព័ន្ធ ។

២-ភាគីរដ្ឋទាំងឡាយត្រូវពិចារណាលើការអភិវឌ្ឍន៍ និងការចែកចាយជំនាញដែលវិភាគពាក់ព័ន្ធសកម្មភាពឧក្រិដ្ឋកម្មជាមួយគ្នា ហើយតាមរយៈអង្គការអន្តរជាតិ និងអង្គការក្នុងតំបន់ចំពោះគោលបំណងនោះនិយមន័យជា ។ ធម្មតាគឺតទ្រឹស្តីវិទ្យា ត្រូវបានអភិវឌ្ឍន៍ និងបានអនុវត្តយ៉ាងត្រឹមត្រូវ ។

៣-ភាគីរដ្ឋនីមួយៗត្រូវពិចារណាជំរុញរបបនយោបាយរបស់ខ្លួននិងវិធានការណ៍ជាក់លាក់ដើម្បីប្រយុទ្ធប្រឆាំងបទឧក្រិដ្ឋ និងបង្កើតការវាយតំលៃនូវប្រសិទ្ធភាព និងភាពគ្រប់គ្រាន់របស់ពួកខ្លួន ។

## មាត្រានី២៩

## ការបណ្តុះបណ្តាល និងជំនួយផ្នែកបច្ចេកទេស

១-ភាគីរដ្ឋនីមួយត្រូវចំពោះភាពចាំបាច់ដ៏ធំធេងផ្តើមអភិវឌ្ឍន៍ ឬកែលំអរកម្មវិធីហ្វឹកហ្វឺនជាក់ស្តែងត្រូវពិគ្រោះដើម្បីកំណត់វាក្យស័ព្ទ និងលក្ខខ័ណ្ឌស្ថិតក្រោមផ្នែកនៃសំណើរនិងត្រូវបានបញ្ចប់ក៏ដូចជាលក្ខណៈដែលតំលៃត្រូវបានបំផ្លាញចោល ។ បណ្តារដ្ឋជាសមាជិកគួរពង្រីកនូវវិសាលភាពចាំបាច់ ផ្តួចផ្តើមឡើង អភិវឌ្ឍន៍ ឬក៏កែលំអរនូវកម្មវិធីបណ្តុះបណ្តាលច្បាស់លាស់សម្រាប់អនុវត្តច្បាប់បុគ្គល ដោយរាប់បញ្ចូលទាំងរាជអាជ្ញា អង្គចៅក្រមស៊ើបអង្កេត និងបុគ្គលិក.គយ ព្រមទាំងបុគ្គលិកដទៃទៀត ដែលបានចោទប្រកាន់ពីការទប់ស្កាត់ ការការពារ ការស្រាវជ្រាវរក និងការ គ្រប់គ្រងអ្នកប្រព្រឹត្តល្មើសដែលបានចែងក្នុងអនុសញ្ញានេះ ។

កម្មវិធីទាំងនេះអាចរួមបញ្ចូលទាំងការផ្ទេរ និងការផ្លាស់ប្តូរបុគ្គលិក និយាយរួមកម្មវិធីនេះអាចជាប់ទាក់ទង ទៅនឹងវិសាលភាពដែលត្រូវជាប់ពាក់ព័ន្ធជាមួយច្បាប់ក្នុងស្រុកដែលមានដូចខាងក្រោមនេះ:

(a)-វិធីសាស្ត្រដែលត្រូវបានប្រើប្រាស់ក្នុងការទប់ស្កាត់ ការឃុំឃាំង និងការគ្រប់គ្រងជនល្មើសដែល មានចែងក្នុងមាត្រានេះ ។

(b)-ផ្លូវជាតិ និងបច្ចេកទេសគ្រប់គ្រងដែលត្រូវបានប្រើដោយមនុស្សដែលសង្ស័យថាជាប់ពាក់ព័ន្ធក្នុង ការប្រព្រឹត្តល្មើស ដោយអនុសញ្ញាបានចែងនេះ រាប់បញ្ចូលទាំងការឆ្លងកាត់តាមបណ្តារដ្ឋ និងវិធានការទប់-ស្កាត់ដ៏សមរម្យ ។

(c)-ការគ្រប់គ្រងចលនារបស់វត្ថុរត់ពន្ធ

(d)-ការស៊ើបអង្កេត និងការគ្រប់គ្រងនូវចលនានៃដំណើរការបទឧក្រិដ្ឋ ទ្រព្យសម្បត្តិ ឧបករណ៍ និង តាមមធ្យោបាយផ្សេងទៀត ព្រមទាំងវិធីសាស្ត្រដែលត្រូវបានប្រើសម្រាប់ការផ្ទេរ ការលាក់បាំង ឬការក្លែង បន្លំនូវការបន្តដំណើរការបែប ទ្រព្យសម្បត្តិ ឧបករណ៍ ឬក៏តាមមធ្យោបាយនៃឧបករណ៍ ព្រមទាំងវិធីសាស្ត្រ ដែលបានប្រើប្រាស់ក្នុងការប្រយុទ្ធប្រឆាំងការលាងលុយកខ្វក់ និងបទល្មើសហិរញ្ញវត្ថុផ្សេងៗទៀត ។

(e)-ការប្រមូលភស្តុតាង

(f)-ការគ្រប់គ្រងផ្នែកបច្ចេកទេសក្នុងតំបន់ពាណិជ្ជកម្មសេរី និងផែសេរី

(g)-ឧបករណ៍ទំនើបសម្រាប់អនុវត្តច្បាប់និងបច្ចេកទេស ដោយរាប់បញ្ចូលទាំងការឈ្លបមើលដោយ ប្រើឧបករណ៍អគ្គិសនី ត្រួតពិនិត្យការចែកចាយ និងកិច្ចប្រតិបត្តិការដោយសម្ងាត់ ។

(h)-វិធីសាស្ត្រដែលបានប្រើប្រាស់ក្នុងការប្រយុទ្ធប្រឆាំងបទឧក្រិដ្ឋឆ្លងដែនដែលបានរៀបចំឡើង និង ប្រព្រឹត្តដោយប្រើប្រាស់តាមរយៈកុំព្យូទ័រទំនាក់ទំនងតាមបណ្តាញប្រព័ន្ធ ឬក៏ទ្រង់ទ្រាយផ្សេងទៀតតាមបែប បច្ចេកវិទ្យាទំនើប និង...

(i)-វិធីសាស្ត្របានប្រើប្រាស់ក្នុងការការពារជនរងគ្រោះ និងសាក្សី

២-បណ្តារដ្ឋជាសមាជិកនឹងជួយគ្នាទៅវិញទៅមកក្នុងការធ្វើគម្រោង និងអនុវត្តនូវការស្រាវជ្រាវ ហើយនិង បណ្តុះបណ្តាលកម្មវិធីដែលបានគ្រោងទុក ដើម្បីចែករំលែកនូវអ្នកជំនាញនៅតាមតំបន់នីមួយៗ ដោយសំដៅយោងទៅ កថាខ័ណ្ឌ ១ នៃមាត្រានេះហើយដែលអាចនឹងបញ្ចប់នៅកថាខ័ណ្ឌនេះផងដែរ នៅពេលដែលសមរម្យរៀបចំនូវសន្និសីទ ថ្នាក់តំបន់ អន្តរជាតិ និងសិក្ខាសាលាដើម្បីជម្រុញកិច្ចសហប្រតិបត្តិការ និងជម្រុញនូវការពិភាក្សាស្តីពីបញ្ហាដែលជាប់ ពាក់ព័ន្ធគ្នាទៅវិញទៅមក ដោយរាប់បញ្ចូលទាំងបញ្ហាដ៏សំខាន់ៗ និងតម្រូវការនៃការឆ្លងកាត់តាមបណ្តារដ្ឋ ។

៣-បណ្តារដ្ឋជាសមាជិកគួរតែជម្រុញនូវការបណ្តុះបណ្តាល និងជំនួយបច្ចេកទេសដែលអាចសម្រួលដល់ការធ្វើ បត្យាប័ន និងជំនួយស្របច្បាប់ទៅវិញទៅមកដូចជា :ការបណ្តុះបណ្តាល និងជំនួយបច្ចេកទេសដែលអាចរាប់បញ្ចូលទាំង ការបណ្តុះបណ្តាលផ្នែកភាសានិងការផ្លាស់ប្តូរបុគ្គលិករវាងអាជ្ញាធរកណ្តាល ឬភ្នាក់ងារទាំងឡាយណាដែលជាប់ពាក់ព័ន្ធ ក្នុងការទទួលខុសត្រូវ ។

៤-ក្នុងករណីដែលមានកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី ឬក៏មានតាមលំដាប់លំដោយ បណ្តារដ្ឋជាសមាជិកនឹងពង្រឹងចំពោះវិសាលភាពដែលចាំបាច់ប្រើងប្រែងបង្កើតអោយមានជាអតិបរមានូវសកម្មភាពប្រតិបត្តិការនិងការបណ្តុះបណ្តាលដែលមានជាប់ពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគីដែលមានតាមលំដាប់លំដោយ ។

## មាត្រា ៣០

## វិធានការផ្សេងៗ

ការអនុវត្តនូវអនុសញ្ញានេះតាមរយៈការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច និងជំនួយសង្គ្រោះផ្នែកបច្ចេកទេសៈ

១-បណ្តារដ្ឋជាសមាជិកគួរតែចាត់វិធានការដែលបណ្តាលអោយមានលក្ខណៈល្អប្រសើរបំផុតក្នុងការអនុវត្តនូវអនុសញ្ញានេះដើម្បីបង្កើនវិធានការដែលអាចអនុវត្តបានតាមរយៈកិច្ចប្រតិបត្តិការជាលក្ខណៈអន្តរជាតិ និងចាត់វិធានការនូវផលប៉ះពាល់ជាអវិជ្ជមាននៃបទឧក្រិដ្ឋដែលបានរៀបចំឡើងក្នុងសង្គមជាទូទៅ និយាយរួមកិច្ចអភិវឌ្ឍន៍ដែលអាចទ្រទ្រង់ទៅបាន ។

២-បណ្តារដ្ឋជាសមាជិកត្រូវបង្កើននូវកិច្ចខិតខំប្រឹងប្រែងដ៏រឹងមាំ ដើម្បីពង្រីកនូវទំហំនៃកិច្ចសម្របសម្រួលគ្នាទៅវិញទៅមកដែលអាចធ្វើទៅបាន ព្រមទាំងមានអង្គការអន្តរជាតិ និងអង្គការប្រចាំតំបន់ផងដែរ ។

(a)-ដើម្បីបង្កើននូវកិច្ចសហប្រតិបត្តិការរបស់ខ្លួននូវកម្រិតផ្សេងៗគ្នាជាមួយនិងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ជាមួយនឹងទស្សនៈវិស័យដោយពង្រឹងនូវសមត្ថភាពចុងក្រោយ ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងបទឧក្រិដ្ឋឆ្លងដែនដែលបានរៀបចំឡើង ។

(b)-ការលើកស្ទួយជំនួយហិរញ្ញវត្ថុនិងសម្ភារៈដើម្បីជួយគាំទ្រនូវកិច្ចខិតខំបឹងប្រែងក្នុងបណ្តាប្រទេសដែលកំពុងអភិវឌ្ឍន៍ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងបទឧក្រិដ្ឋឆ្លងដែនដែលបានរៀបចំឡើង ហើយនិងដើម្បីជួយប្រទេសទាំងនោះក្នុងការអនុវត្តន៍អនុសញ្ញានេះអោយបានជោគជ័យ ។

(c)-ផ្តល់ជំនួយបច្ចេកទេសទៅដល់បណ្តាប្រទេសដែលកំពុងអភិវឌ្ឍន៍ និងបណ្តាប្រទេសដែលមានសេដ្ឋកិច្ចស្ថិតក្នុងសម័យអន្តរកាល ដើម្បីជួយដល់បណ្តាប្រទេសទាំងអស់នោះសម្រាប់បំពេញនូវសេចក្តីត្រូវការរបស់ពួកគេសម្រាប់អនុវត្តនូវអនុសញ្ញានេះ ។ចំពោះសេចក្តីបញ្ចប់នោះបណ្តារដ្ឋជាសមាជិកនឹងគោរពស្រឡាញ់សេចក្តីត្រូវការរបស់ខ្លួន ដើម្បីប្រកាន់ខ្ជាប់ការស្ម័គ្រចិត្តរួមចំណែកដោយទៀងទាត់តាមច្បាប់ ចំពោះសេចក្តីអធិប្បាយដែលត្រូវបានជ្រើសរើសយកជាក់ស្តែងសម្រាប់គោលបំណងខាងលើនោះ ក្នុងយន្តការមូលនិធិរបស់អង្គការសហប្រជាជាតិ បណ្តារដ្ឋជាសមាជិកអាចផ្តល់នូវការពិចារណាដ៏ពិសេសមួយផងដែរដោយអនុលោមទៅតាមច្បាប់របស់ប្រទេសខ្លួន និងខដែលបានចែងនៅក្នុងអនុសញ្ញានេះដើម្បីរួមចំណែក និងសេចក្តីអធិប្បាយដែលបានថ្លែងរួចមកនូវភាគរយនៃមូលនិធិ ឬតម្លៃនៃប្រាក់ចំណូលចំណាយដែលស្របទៅនឹងបទឧក្រិដ្ឋ ឬក៏ទ្រព្យសម្បត្តិដែលត្រូវបានរឹបអូសយកស្របទៅនឹងខដែលបានចែងក្នុងអនុសញ្ញានេះ ។

(d)-លើកទឹកចិត្ត និងបញ្ចុះបញ្ចូលបណ្តារដ្ឋដទៃផ្សេងទៀត និងផ្តល់ជាហិរញ្ញវត្ថុដល់បណ្តាស្ថាប័នអោយបានសមស្របជាចំណែងចងភ្ជាប់នៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន អោយស្របទៅនឹងមាត្រានេះជាពិ-

សេសផ្ដល់នូវកម្មវិធីបណ្ដុះបណ្ដាលបន្ថែមទៀត និងឧបករណ៍ទំនើបអោយទៅបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីជួយដល់បណ្ដាប្រទេសទាំងនោះក្នុងការសម្រេចគោលដៅនៃអនុសញ្ញានេះ ។

៣-ចំពោះវិសាលភាពដែលអាចធ្វើទៅបាន វិធានការទាំងអស់នេះនឹងមិនធ្វើអោយខូចប្រយោជន៍ដល់សេចក្ដីប្ដេជ្ញាចិត្តជាជំនួយបរទេសដែលមានរួចជាស្រេច ឬក៏ចំពោះកិច្ចប្រតិបត្តិការហិរញ្ញវត្ថុដែលមានជាហូរហែរនៅក្នុងសេចក្ដីព្រមព្រៀងទ្វេភាគីក្នុងតំបន់ ឬក៏ក្នុងកម្រិតអន្តរជាតិ ។

៤-បណ្ដារដ្ឋជាសមាជិកអាចសន្និដ្ឋាននូវសេចក្ដីព្រមព្រៀងទ្វេភាគី ឬពហុភាគី ឬក៏សេចក្ដីព្រមព្រៀងដែលមានជាហូរហែរស្ដីពីសម្ភារៈនិងជំនួយសមហេតុផល ដើម្បីពិចារណាអោយបានសមស្របនូវហិរញ្ញវត្ថុដែលចាំបាច់ជាលំដាប់-លំដោយនូវរាល់មធ្យោបាយនៃកិច្ចសហប្រតិបត្តិការអន្តរជាតិដែលបានចែងដោយអនុសញ្ញានេះ ដើម្បីធ្វើអោយមានប្រ-សិទ្ធភាព និងសម្រាប់ការទប់ស្កាត់ ការស្រាវជ្រាវ និងការត្រួតពិនិត្យមើលនូវបទឧក្រិដ្ឋឆ្លងដែនដែលបានរៀបចំឡើង ។

## មាត្រា ៣១

## វិធានការបង្ការ និងការពារ

១-បណ្ដារដ្ឋជាសមាជិកត្រូវរៀបចំខ្លួនអោយបានល្អ ដើម្បីអភិវឌ្ឍន៍ និងវាយតម្លៃនូវគម្រោងផែនការរបស់ជាតិ ហើយដើម្បីបង្កើតឡើងនិងជម្រុញនូវការអនុវត្តអោយបានល្អប្រសើរបំផុត និងគោលនយោបាយទាំងឡាយ ដើម្បីសំដៅទៅរកការទប់ស្កាត់នូវបទឧក្រិដ្ឋឆ្លងដែនដែលបានរៀបចំឡើង ។

២-បណ្ដារដ្ឋជាសមាជិកគួរតែយកចិត្តទុកដាក់ដោយអនុលោមទៅតាមច្បាប់របស់ប្រទេសរបស់ខ្លួន ដែលជាមូលដ្ឋានគ្រឹះដើម្បីកាត់បន្ថយឱកាសដែលមានស្រាប់ ឬក៏ច្បាប់ដែលមាននាពេលអនាគតរបស់ក្រុមឧក្រិដ្ឋកម្មដែលបានរៀបចំឡើង ដែលស្របតាមច្បាប់ទីផ្សារនៃបទឧក្រិដ្ឋប្រាក់ចំណូល តាមរយៈនីតិបញ្ញត្តិដ៏សមរម្យ រដ្ឋបាល ឬក៏វិធានការផ្សេងៗទៀត បណ្ដាវិធានការទាំងអស់នេះគួរតែផ្ដោតការយកចិត្តលើ :

(a)-ពង្រឹងកិច្ចប្រតិបត្តិការរវាងស្ថាប័នច្បាប់ ឬក៏ព្រះរាជអាជ្ញា និងអង្គភាពឯកជនដែលជាប់ពាក់ព័ន្ធដោយរាប់បញ្ចូលទាំងឧស្សាហកម្ម ។

(b)-ការជម្រុញនូវកម្រិតអភិវឌ្ឍន៍ និងនីតិក្រមដែលបានតាក់តែងឡើងដើម្បីការពារផលប្រយោជន៍សាធារណៈ និងអង្គភាពឯកជនដែលជាប់ពាក់ព័ន្ធ ព្រមទាំងច្បាប់ទូទានខ្លួនដែលទាក់ទិនទៅនឹងវិជ្ជាជីវៈជាពិសេសមេធាវី សារការី ទីប្រឹក្សាពន្ធ និងគណនេយ្យករ ។

(c)-ការពារនូវការប្រើប្រាស់មិនត្រឹមត្រូវដោយក្រុមឧក្រិដ្ឋជនដែលរៀបចំឡើងនូវនិន្នាការនីតិក្រមដែលបានប្រព្រឹត្តឡើងដោយអាជ្ញាធរទូទៅ និងការជំនួយជាប្រាក់ និងអជ្ញាប័ណ្ណដែលបានផ្ដល់អោយដោយអាជ្ញាធរទូទៅសម្រាប់សកម្មភាពដែលទាក់ទងនឹងពាណិជ្ជកម្ម ។

(d)-ការការពារនូវការប្រើប្រាស់មិនត្រឹមត្រូវ នូវនីតិបុគ្គលដោយក្រុមឧក្រិដ្ឋកម្មដែលបានរៀបចំឡើងដូចជាវិធានការទាំងឡាយដែលអាចរាប់បញ្ចូលបាន:

(i)-ការបង្កើតឡើងនូវការិយាល័យតម្កល់ឯកសារច្បាប់ដែលជាប់ពាក់ព័ន្ធនឹងការបង្កើតឡើងនូវមនុស្សពីកំណើត ការគ្រប់គ្រង និងការផ្ដល់ប្រាក់ដល់នីតិបុគ្គល ។

(ii)-ការណែនាំនូវលទ្ធភាពនៃការដកហូតសិទ្ធដោយសាលក្រមរបស់តុលាការ ឬក៏មធ្យោបាយសមស្របផ្សេងទៀតសម្រាប់អំឡុងពេលដ៏សមរម្យមួយចំពោះជនណាដែលត្រូវបានកាត់អោយជាប់ទោសពីការរំលោភច្បាប់ដែលបានចែងក្នុងអនុសញ្ញានេះ ដូចជាសកម្មភាពនីតិបុគ្គលរបស់គណៈនាយកដែលមាននៅក្នុងអំណាចច្បាប់របស់ខ្លួន ។

(iii)-ការបង្កើតឡើងនូវប័ណ្ណសារជាតិរបស់មនុស្សដែលត្រូវបានគេដកចេញពីគណនាយករបស់នីតិបុគ្គល ហើយនិង

(iv)-ការផ្លាស់ប្តូរពត៌មានដែលមាននៅក្នុងកំណត់ហេតុដែលយោងទៅរកអនុមាត្រា (d) (i) (iii) របស់កឋាខ័ណ្ឌ ជាមួយនឹងអាជ្ញាធរដែលមានសមត្ថកិច្ចនៃបណ្តារដ្ឋជាសមាជិក ។

៣-បណ្តារដ្ឋជាសមាជិកទាំងអស់ប្រឹងប្រែងជម្រុញអោយមានការប្រគល់មកវិញនូវមនុស្សណាដែលបានប្រព្រឹត្តបទឧក្រិដ្ឋ និងដែលត្រូវបានកាត់អោយជាប់ទោស ដូចដែលបានចែងក្នុងអនុសញ្ញានេះ ។

៤-បណ្តារដ្ឋជាសមាជិកទាំងអស់គួរតែប្រឹងប្រែងដើម្បីវាយតម្លៃនូវឯកសារពាក់ព័ន្ធ ច្បាប់ដែលមានយូរៗម្តង និងការអនុវត្តន៍ដែលតាមបែបរដ្ឋបាល តាមទស្សនៈវិស័យដើម្បីស្រាវជ្រាវការប្រព្រឹត្តមិនត្រឹមត្រូវរបស់ពួកគេដែលបណ្តាលអោយមានការងាយស្រួល ឆាប់ខូចខាតដែលបង្កឡើងដោយក្រុមឧក្រិដ្ឋជនដែលបានរៀបចំឡើង ។

៥-បណ្តារដ្ឋជាសមាជិកទាំងអស់គួរតែប្រឹងប្រែងជម្រុញអោយមានការប្រុងប្រយ័ត្នជាសាធារណៈចំពោះច្បាប់ដែលមានរួចជាស្រេច បុព្វហេតុនិងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ និងការគំរាមកំហែងដែលបានបង្កឡើងដោយបទឧក្រិដ្ឋឆ្លងដែនដែលបានរៀបចំឡើង ។ ពត៌មាននេះអាចត្រូវបានចែកចាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយពត៌មានដ៏ច្រើនសមរម្យ ហើយនិងរាប់បញ្ចូលទាំងវិធានការនានាដើម្បីជម្រុញអោយមានការចូលរួមជាសាធារណៈក្នុងការការពារ និងប្រយុទ្ធប្រឆាំងនូវបទឧក្រិដ្ឋទាំងនេះ ។

៦-បណ្តារដ្ឋជាសមាជិកនីមួយៗគួរតែ ជម្រាបជូនលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ នូវឈ្មោះអាសយដ្ឋានរបស់អាជ្ញាធរ ឬក៏គ្រប់អាជ្ញាធរទាំងអស់ដែលអាចជួយដល់វិធានការកំពុងអភិវឌ្ឍន៍ ដល់បណ្តារដ្ឋដែលជាសមាជិកដើម្បីទប់ស្កាត់នូវបទឧក្រិដ្ឋកម្មឆ្លងដែនដែលបានរៀបចំឡើង ។

៧-បណ្តារដ្ឋជាសមាជិកទាំងអស់គួរតែធ្វើអោយសមរម្យ ដោយធ្វើការសហការរួមគ្នាទៅវិញទៅមក ជាមួយនឹងអង្គការអន្តរជាតិ អង្គការតំបន់ដែលជាប់ពាក់ព័ន្ធក្នុងការជម្រុញ និងអភិវឌ្ឍន៍វិធានការដែលមាននៅក្នុងមាត្រានេះ ដោយរាប់បញ្ចូលទាំងការចូលរួមចំណែកនូវគម្រោងជាលក្ខណៈអន្តរជាតិ សំដៅទៅរកការការពារនូវបទឧក្រិដ្ឋឆ្លងដែនដែលបានរៀបចំឡើង ហើយនោះជាឧទាហរណ៍ដោយមានការកាត់បន្ថយនូវករណីដូចនេះដែលប្រគល់ជូនមកវិញដល់ក្រុមទាំងនោះតាមបែបសង្គមជាបន្ទាប់បន្សំ ដែលប៉ះពាល់ដល់សកម្មភាពនៃបទឧក្រិដ្ឋឆ្លងដែនដែលបានរៀបចំឡើង ។

## មាត្រា ៣២

## សន្និសីទស្តីពីអនុសញ្ញារបស់បណ្តាគូភាគី

១-សន្និសីទស្តីពីអនុសញ្ញារបស់បណ្តាគូភាគីគឺ ត្រូវបានបង្កើតឡើងតាមរយៈនៃការកែលំអរនូវសមត្ថភាពនៃបណ្តារដ្ឋដែលជាសមាជិកដើម្បីប្រយុទ្ធប្រឆាំងទៅនឹងបទឧក្រិដ្ឋឆ្លងដែនដែលបានចាត់តាំងឡើង និងដើម្បីជម្រុញ និងរំលើកឡើងវិញនូវការអនុវត្តនៃអនុសញ្ញានេះ ។

២-អគ្គលេខាធិការអង្គការសហប្រជាជាតិគួរតែកោះហៅប្រជុំអោយមានសន្និសីទថ្នាក់ភាគី ដោយមិនអោយយឺតហួសពីរយៈពេលមួយឆ្នាំ ដោយអនុវត្តតាមការចូលជាធរមាននូវអនុសញ្ញានេះ ។ សន្និសីទរបស់បណ្តាគូភាគីគួរតែអនុម័តទម្រង់ការច្បាប់ទាំងឡាយ និងច្បាប់សម្រាប់គ្រប់គ្រងនូវរាល់សកម្មភាពដូចបានចែងក្នុងកឋាខ័ណ្ឌ ៣ និង ៤

របស់មាត្រានេះ ដោយរាប់បញ្ចូលទាំងច្បាប់ទាំងឡាយដែលជាប់ពាក់ព័ន្ធទៅនឹងសោហ៊ុយសម្រាប់អ្នកការពារក្ដីដែលបានជួបប្រទះក្នុងការអនុវត្តន៍នូវរាល់សកម្មភាពទាំងអស់នោះ ។

៣-កិច្ចប្រជុំនៃរាល់បណ្ដាគូភាគីនឹងត្រូវបានព្រមព្រៀងគ្នាទៅតាមយន្តការខាងលើ ដើម្បីសម្រេចនូវគោលដៅដូចដែលបានចែងនៅក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ ដោយរួមមានទាំង :

a)-រាល់សកម្មភាពដែលបានសម្រួលដោយបណ្ដារដ្ឋជាសមាជិកនោះស្ថិតនៅក្រោមមាត្រា ២៩ ៣០ និង ៣១ នៃអនុសញ្ញានេះដោយរាប់បញ្ចូលទាំងការលើកទឹកចិត្តនៃការប្រមូលផ្ដុំ ជួយជាវិភាគទានដោយស្ម័គ្រចិត្ត ។

(b)-ផ្ដល់ភាពងាយស្រួលដល់ការផ្លាស់ប្ដូរពត៌មានក្នុងចំណោមបណ្ដារដ្ឋជាសមាជិកទាំងអស់ស្ដីពីលំនាំនិងទិសដៅក្នុងបទឧក្រិដ្ឋកម្មឆ្លងដែនដែលបានរៀបចំឡើង ហើយនិងអនុវត្តអោយបានជោគជ័យក្នុងការប្រយុទ្ធប្រឆាំងទៅនឹងបទឧក្រិដ្ឋនេះ ។

(c)-ធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការជាតិ និងអន្តរជាតិ ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធជាច្រើនទៀត ។

(d)-យូរៗម្ដងធ្វើការលើកឡើងវិញនូវការអនុវត្តនៃអនុសញ្ញានេះ ។

(e)-ធ្វើការធានាអះអាងដើម្បីអោយប្រសើរឡើងនូវអនុសញ្ញានេះហើយនិងការអនុវត្តរបស់ខ្លួន ។

៤-ចំពោះគោលបំណងនៃកថាខ័ណ្ឌ ៣ (d) និង (e) នៃមាត្រានេះ កិច្ចប្រជុំនៃរាល់បណ្ដាគូភាគីនឹងត្រូវទទួលបាននូវចំណេះដឹងផ្ទាល់ខ្លួនជាចាំបាច់ដើម្បីចាត់នូវរាល់វិធានការក្នុងការអនុវត្តន៍អនុសញ្ញានេះ ហើយនិងមានការលំបាកជាច្រើនដែលពួកគេបានជួបប្រទះតាមរយៈការទំនាក់ទំនងដែលត្រូវផ្ដល់អោយដោយពួកគេតាមរយៈការបំពេញបន្ថែមនូវយន្តការដែលត្រូវពិនិត្យឡើងវិញដែលអាចនឹងត្រូវបានបង្កើតឡើងតាមកិច្ចប្រជុំរបស់បណ្ដាគូភាគី ។

៥-រដ្ឋនីមួយៗដែលជាសមាជិកនឹងត្រូវផ្ដល់អោយនូវកិច្ចប្រជុំរបស់បណ្ដាគូភាគី ជាមួយនិងគម្រោងផែនការកម្មវិធី និងការអនុវត្តន៍របស់ខ្លួនអោយបានត្រឹមត្រូវតាមច្បាប់ព្រមទាំងបណ្ដាវិធានការផ្នែករដ្ឋបាល ដើម្បីអនុវត្តនូវអនុសញ្ញានេះតាមតម្រូវការកិច្ចប្រជុំរបស់រាល់បណ្ដាគូភាគី ។

## មាត្រា ៣៣

## លេខាធិការដ្ឋាន

១-អគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិ នឹងផ្ដល់អោយនូវភាពចាំបាច់នៃសេវាកម្មផ្នែកលេខាធិការដ្ឋានជូនដល់កិច្ចប្រជុំនៃរាល់បណ្ដាគូភាគីចំពោះអនុសញ្ញានេះ ។

២-ផ្នែកលេខាធិការដ្ឋាននឹង :

(a)-ជួយដល់កិច្ចប្រជុំរបស់បណ្ដាគូភាគីទៅក្នុងការអនុវត្តនូវរាល់សកម្មភាព ដូចដែលបានចែងក្នុងមាត្រា ៣២ នៃអនុសញ្ញានេះ ហើយនិងបង្កើតឡើងនូវការចាត់ចែងព្រមទាំងផ្ដល់អោយនូវសេវាកម្មដ៏ចាំបាច់ចំពោះកិច្ចប្រជុំនៃអង្គសន្និសីទរបស់បណ្ដាគូភាគី ។

(b)-ស្នើសុំជំនួយចំពោះបណ្តារដ្ឋដែលជាសមាជិកខាងលើ ក្នុងការផ្តល់អោយនូវពត៌មានជូនដល់កិច្ចប្រជុំរបស់បណ្តាគូភាគីដែលបានគ្រោងទុកជាមុននៅក្នុងមាត្រា ៣២ កថាខ័ណ្ឌ ៥នៃអនុសញ្ញានេះ ហើយនឹង

(c)-ធានានូវការសំរបសំរួលដ៏ចាំបាច់មួយ នឹងផ្នែកលេខាធិការដ្ឋានដែលពាក់ព័ន្ធទៅនឹងអង្គការតាមតំបន់ និងអង្គការអន្តរជាតិ ។

## មាត្រា ៣៤

## ការអនុវត្តន៍អនុសញ្ញា

១-រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់របស់ខ្លួនរួមមាន វិធានការនីតិបញ្ញត្តិ និងវិធានការរដ្ឋបាលអនុលោមតាមគោលការណ៍នៃច្បាប់ជាតិដើម្បីធានាការអនុវត្តន៍កាតព្វកិច្ចដែលចែងក្នុងអនុសញ្ញានេះ ។

២-បទល្មើសទាំងឡាយដែលបានកំណត់ក្នុងមាត្រា៥, ៦, ៨ និងមាត្រា ២៣ នៃអនុសញ្ញានេះ ត្រូវតែកំណត់ក្នុងច្បាប់ជាតិនៃរដ្ឋភាគីនីមួយៗ ដាច់ចេញពីលក្ខណៈអន្តរជាតិ ឬការពាក់ព័ន្ធនឹងក្រុមឧក្រិដ្ឋកម្មរៀបចំដូចបានរៀបរាប់ក្នុងមាត្រា ៣ វាក្យខ័ណ្ឌទី ១ នៃអនុសញ្ញានេះ លើកលែងតែប្រការ មាត្រា ៥ តម្រូវអោយមានកា ពាក់ព័ន្ធទៅនឹងក្រុមឧក្រិដ្ឋកម្មរៀបចំ ។

៣- រដ្ឋភាគីនីមួយៗអាចអនុម័ត វិធានការហ្មឹងម៉ាត់ ឬតឹងរឹង ជាងវិធានការដែលចែងក្នុងអនុសញ្ញានេះដើម្បីទប់ស្កាត់ និង ប្រឆាំងនឹងឧក្រិដ្ឋកម្មរៀបចំអន្តរជាតិ ។

## មាត្រា ៣៥

## ការដោះស្រាយវិវាទ

១-រដ្ឋភាគីទាំងអស់ត្រូវតែប្រើកិច្ចប្រឹងប្រែង ដើម្បីដោះស្រាយវិវាទទាំងឡាយទាក់ទិននឹងការបកស្រាយ ឬអនុវត្តអនុសញ្ញាតាមរយៈការចរចា ។

២-រាល់វិវាទរវាងភាគីពីរ ឬច្រើនទាក់ទិននឹងការបកស្រាយ និងការអនុវត្តន៍អនុសញ្ញានេះដែលមិនអាចដោះស្រាយតាមការចរចាក្នុងរយៈពេលសមស្របត្រូវដាក់ជូនមជ្ឈត្តកម្មដោះស្រាយតាមសំណើរបស់ភាគីណាមួយអាចបញ្ជូនវិវាទនេះទៅដោះស្រាយនៅតុលាការយុត្តិធម៌អន្តរជាតិតាមសំណើ អនុលោមទៅតាមច្បាប់លក្ខន្តិកៈនៃតុលាការនោះ ។

៣-រដ្ឋភាគីនីមួយៗអាចធ្វើសច្ចាប័នទទួលយក ឬយល់ព្រមលើ ឬចូលជាសមាជិកនៅពេលចុះហត្ថលេខា ដោយ

ប្រកាសថាខ្លួនសំរេចមិនត្រូវភ្ជាប់កាតព្វកិច្ចតាមវាក្យខ័ណ្ឌទី២ នៃមាត្រានេះបាន ។ រដ្ឋភាគីដទៃទៀតមិនត្រូវភ្ជាប់កាតព្វកិច្ចទៅតាមវាក្យខ័ណ្ឌទី២ នៃមាត្រានេះឡើយ ចំពោះរដ្ឋភាគីដែលបានប្រកាសទុកបំរុងវាក្យខ័ណ្ឌនេះឡើយ ។

៤-រដ្ឋភាគីដែលបានប្រកាសបំរុងទុក អនុលោមតាមវាក្យខ័ណ្ឌទី ៣ នៃមាត្រានេះអាចដកហូតការបំរុងនេះនៅពេលណាក៏បានតាមរយៈការជូនដំណឹងទៅអគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិ ។

## មាត្រា ៣៦
## ហត្ថលេខា សច្ចាប័ន ការទទួលយក ការយល់ព្រម និងការចូលជាសមាជិក

១-អនុសញ្ញានេះត្រូវបើកចំហសំរាប់រដ្ឋទាំងអស់ចុះហត្ថលេខា ពីថ្ងៃទី ១២ ដល់ថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០០០ នៅទីក្រុងប៉ាឡឺម៉ូ ប្រទេសអ៊ីតាលី និងបន្ទាប់ពីនោះនៅការិយាល័យអង្គការសហប្រជាជាតិ ទីក្រុង ញ៉ូវ យ៉ក រហូតដល់ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០០២ ។

២-អនុសញ្ញានេះក៏បើកចំហ សំរាប់រដ្ឋទាំងអស់ចុះហត្ថលេខា ដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចប្រចាំតំបន់ កាលណាមានរដ្ឋសមាជិកយ៉ាងហោចណាស់មួយបានចុះហត្ថលេខាលើអនុសញ្ញានេះស្របតាមវាក្យខ័ណ្ឌទី ១ នៃមាត្រា នេះ ។

៣-អនុសញ្ញានេះអាចត្រូវបានធ្វើសច្ចាប័នទទួលស្គាល់ ឬ ឯកភាពបាន ។ លិខិតូបករណ៍នៃការធ្វើសច្ចាប័ន ឬ ឯកភាពដោយតំកល់នៅអគ្គលេខាអង្គការសហប្រជាជាតិ ។ អង្គការសមាហរណកម្មសេដ្ឋកិច្ចប្រចាំតំបន់អាចតំកល់លិខិតូបករណ៍នៃការធ្វើសច្ចាប័នការទទួលស្គាល់ ឬការឯកភាពអង្គការទាំងនោះ ត្រូវប្រកាសសមត្ថភាពរបស់ខ្លួន ដែលទាក់ទិននឹងបញ្ហាដែលចែងក្នុងអនុសញ្ញានេះ ។ អង្គការទាំងនេះក៏ត្រូវជូនដំណឹងពីការតំកល់វិសោធនកម្មដែលបានធ្វើក្នុងសមត្ថកិច្ចរបស់ខ្លួនផងដែរ ។

៤-អនុសញ្ញានេះបើកចំហដើម្បីអោយរដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចចូលជាសមាជិក ដែលក្នុងនោះមានសមាជិកមួយជាហត្ថលេខីនៃអនុសញ្ញានេះ ។ លិខិតូបករណ៍នៃការចូលជាសមាជិកត្រូវតម្កល់នៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ នៅពេលចូលជាសមាជិក អង្គការសមាហរណកម្មសេដ្ឋកិច្ច ប្រចាំតំបន់ត្រូវប្រកាសពីសមត្ថភាពរបស់ខ្លួនទាក់ទិននឹងបញ្ហាដែលចែងក្នុងអនុសញ្ញានេះ ។ អង្គការទាំងនេះក៏ត្រូវជូនដំណឹងពីការតម្កល់វិសោធនកម្មដែលបានធ្វើក្នុងសមត្ថកិច្ចរបស់ខ្លួនផងដែរ ។

## មាត្រា ៣៧

## ការជំនាក់ជំនងជាមួយពិធីសារ

១-អនុសញ្ញានេះអាចត្រូវបានបន្ថែមដោយពិធីសារមួយ ឬច្រើន។

២-ដើម្បីក្លាយជាភាគីមួយចំពោះពិធិសារនេះរដ្ឋមួយ ឬអង្គការសមាហរ័ណកម្មសេដ្ឋកិច្ចនៅតាមតំបន់ត្រូវតែជាភាគីមួយចំពោះអនុសញ្ញានេះផងដែរ ។

៣-រដ្ឋជាសមាជិកចំពោះអនុសញ្ញានេះមិនត្រូវបានភ្ជាប់ដោយពិធីសារមួយទេ ប្រសិនបើខ្លួនមិនក្លាយជាភាគីចំពោះពិធីសារអនុលោមតាមបញ្ញត្តិទាំងឡាយក្នុងនោះ ។

៤-ពិធីសារណាមួយចំពោះអនុសញ្ញានេះត្រូវបានបកស្រាយរួមគ្នាជាមួយអនុសញ្ញានេះ ចូលជាធរមានចំពោះគោលបំណងនៃពិធីសារនេះ។

## មាត្រា ៣៨

## ការចូលជាធរមាន

១-អនុសញ្ញានេះត្រូវចូលជាធរមានរយៈពេល ៩០ ថ្ងៃ បន្ទាប់ថ្ងៃតម្កល់ឯកសារលើកទី ៤០ នៃការអោយសច្ចានុម័ត ការទទួលយក ការឯកភាព ឬការយល់ព្រម ។ ចំពោះគោលបំណងនៃកថាខ័ណ្ឌនេះ ឯកសារមួយបានតម្កល់ដោយអង្គការសមាហរ័ណកម្មសេដ្ឋកិច្ចតំបន់ នឹងមិនត្រូវបានរាប់បញ្ចូលជាបន្ថែមចំពោះឯកសារនោះ ដែលបានតម្កល់ដោយរដ្ឋជាសមាជិករបស់ អង្គការនេះ ។

២-ចំពោះភាគីរដ្ឋនីមួយៗ ឬអង្គការសមាហរ័ណកម្មសេដ្ឋកិច្ចតំបន់ ការអោយសច្ចាប័ន ការទទួលយក ការឯកភាព ឬការចូលដល់អនុសញ្ញានេះក្រោយពេលចូលជាធរមានរយៈពេល ៣០ ថ្ងៃ បន្ទាប់ថ្ងៃតម្កល់ដោយរដ្ឋ ឬអង្គការដែលឯកសារពាក់ព័ន្ធ ។

## មាត្រា ៣៩

## ការធ្វើវិសោធនកម្ម

១-ក្រោយពេលផុតកំណត់ ៥ ឆ្នាំ នូវការចូលជាធរមាននៃអនុសញ្ញានេះ រដ្ឋជាសមាជិកអាចស្នើសុំធ្វើវិសោធនកម្ម ហើយតម្កល់វាទៅលេខាធិការដ្ឋានអង្គការសហប្រជាជាតិ ដែលជាអ្នកទំនាក់ទំនងការធ្វើវិសោធនកម្មដែលបានស្នើទៅរដ្ឋជាសមាជិក និងទៅសន្និសីទនៃភាគីទាំងអស់ចំពោះអនុសញ្ញាតាម គោលបំណងនៃការពិចារណា និងសម្រេចលើសំណើរ ។សន្និសីទភាគីរដ្ឋត្រូវយកចិត្តទុកដាក់ដើម្បីជម្រុញសមាមាត្រលើវិសោធនកម្មនីមួយៗ។ ប្រសិនបើការទាំងអស់គ្មានការឯកភាពគ្នាមានភាពសោះកក្រោះហើយកិច្ចព្រមព្រៀង មិនត្រូវបានឈានដល់ការធ្វើវិសោធនកម្ម ( ជាមធ្យោបាយដោះស្រាយចុងក្រោយ ) ត្រូវស្នើសុំការអនុម័តរបស់ខ្លួនដោយសម្លេងឆ្នោតជាអតិបរិមា ២/៣ នៃរដ្ឋជាសមាជិកទាំងអស់ដែលមានវត្តមាន ហើយបោះឆ្នោតនៅអង្គប្រជុំសន្និសីទរបស់ភាគីទាំងអស់ ។

២-អង្គការសមាហរ័ណកម្មសេដ្ឋកិច្ចក្នុងតំបន់ ក្នុងករណីតាមរយៈសមត្ថកិច្ចរបស់ខ្លួន នឹងត្រូវអនុវត្តនូវសិទ្ធិរបស់ខ្លួនដើម្បីបោះឆ្នោតតាមមាត្រានេះ ដោយចំនួនឆ្នោតសមមូលទៅនឹងចំនួនរដ្ឋជាសមាជិកដែលជាភាគីចំពោះអនុ-

សញ្ញានេះ ។ អង្គការទាំងនេះមិនត្រូវប្រើប្រាស់សិទ្ធិរបស់ខ្លួនបោះឆ្នោតទេ ប្រសិនបើរដ្ឋជាសមាជិករបស់ខ្លួនប្រើប្រាស់សិទ្ធិរបស់ខ្លួន និងផ្ទុយទៅវិញ ។

៣-វិសោធនកម្មអនុម័តអនុលោមតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ ផ្អែកតាមការអោយសច្ចាប័ន ការទទួលយក ឬការឯកភាពដោយរដ្ឋជាសមាជិកទាំងអស់ ។

៤-វិសោធនកម្មបានអនុម័តអនុលោមតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ នឹងត្រូវចូលជាធរមានចំពោះរដ្ឋជាសមាជិកមួយរយៈពេល ៩០ ក្រោយពីថ្ងៃនៃការដាក់តម្កល់ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ នូវឯកសារអោយសច្ចាប័ន ការទទួលយក ឬការឯកភាពអំពីវិសោធនកម្មនេះ ។

៥-នៅពេលវិសោធនកម្មចូលជាធរមានវាភ្ជាប់រដ្ឋជាសមាជិកទាំងនេះដែលបានបញ្ជាក់ការព្រមព្រៀងរបស់ខ្លួនត្រូវបានភ្ជាប់ដោយវិសោធនកម្មនេះ ។ ភាគីរដ្ឋជាសមាជិកដទៃទៀតនូវតែត្រូវបានភ្ជាប់ដោយបញ្ញត្តិនៃអនុសញ្ញានេះ ហើយវិសោធនកម្មមុនៗដែលបានអោយសច្ចាប័ន បានទទួលយក ឬបានឯកភាព ។

## មាត្រា ៤០

## មោឃភាព

១-រដ្ឋជាសមាជិកអាចចាត់ជាមោឃៈនូវអនុសញ្ញានេះ ដោយបញ្ជាក់អះអាងជាលាយលក្ខណ៍អក្សរជូនដល់អគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ការចាត់ជាមោឃៈនេះនឹងត្រូវមានប្រសិទ្ធិភាពរយៈពេល ១ ឆ្នាំ បន្ទាប់ពីថ្ងៃទទួលការការបញ្ជាក់ដោយអគ្គលេខា ។

២-អង្គការសមាហរ័ណកម្មសេដ្ឋកិច្ចតំបន់ ត្រូវផ្អាកជាភាគីមួយចំពោះអនុសញ្ញានេះកាលណាសមាជិករបស់ខ្លួនទាំងអស់បានដាក់ជាមោឃភាព ។

៣-ការដាក់ជាមោឃៈភាពនូវអនុសញ្ញានេះស្របតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ ត្រូវតម្រូវអោយមោឃភាពនៃពិធីសារនានានោះ ។

## មាត្រា ៤១

## ការចុះបញ្ជី និងភាសា

១-អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបានរៀបចំជាមុននូវការចុះបញ្ជីនៃពិធីសារនេះ ។

២-ច្បាប់ដើមនៃពិធីសារនេះមានភាសា អារ៉ាប់ ចិន អង់គ្លេស បារាំង អេស្ប៉ាញ និងរុស្ស៊ី ។ រាល់អត្ថបទទាំងអស់ពិតជាត្រឹមត្រូវទៅតាមច្បាប់ពិតប្រាកដដែលនឹងបានដាក់ចេញដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ដើម្បីជាសាក្សីក្នុងច្បាប់ទាំងនេះ រាល់តំណាងទាំងអស់ត្រូវចុះហត្ថលេខានៅខាងក្រោមទៅតាមការអនុញ្ញាតដ៏ត្រឹមត្រូវចំពោះអនុសញ្ញានេះ ដោយតំណាងរដ្ឋាភិបាលរៀងៗខ្លួនរបស់គេបានចុះហត្ថលេខាលើពិធីសារនេះ ។